ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៣...សរណន

# សារាចរណែនាំ
# ស្តីពី
# ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣

## ១-សេចក្តីផ្តើម

ក្នុងបរិការណ៍នៃការរាតត្បាតនៃជំងឺកូវីដ-១៩, ដែលធ្វើឱ្យស្ថានភាពម៉ាក្រូសេដ្ឋកិច្ចពិបាកប៉ាន់ប្រមាណឱ្យបានច្បាស់លាស់គ្រប់គ្រាន់នៅដើមឆ្នាំ ២០២០ សម្រាប់សកលលោកទាំងមូល រួមទាំងសម្រាប់កម្ពុជាផងដែរ, រាជរដ្ឋាភិបាលបានសម្រេចពន្យាពេលរៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងសារាចរណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិកា មករៀបចំរួមគ្នាជាមួយនឹងការរៀបចំសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ដែលត្រូវដាក់ចេញនៅសប្តាហ៍ទី១ នៃខែ មិថុនា នេះតែម្តង។ ក្រោយពីបានតាមដានការវិវត្តនៃស្ថានភាពជំងឺកូវីដ-១៩ និងវាយតម្លៃឡើងវិញពីផលប៉ះពាល់មកលើសេដ្ឋកិច្ច-សង្គម ដោយយកចិត្តទុកដាក់, រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ដែលផ្តល់ជាមូលដ្ឋានដល់គ្រប់ក្រសួង-ស្ថាប័នរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ និងការលើកគម្រោងថវិកាប្រចាំឆ្នាំ ២០២១។

ផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលត្រូវដាក់ចេញសារាចរណែនាំស្តីពីការៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ ដើម្បីផ្តល់គោលការណ៍ណែនាំថ្មីៗ និងមគ្គុទ្ទេសបច្ចេកទេសគន្លឹះៗ សម្រាប់គ្រប់ក្រសួង-ស្ថាប័នធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិកា (៣ ឆ្នាំរំកិល) ដែលពេលនេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមក្រសួង-ស្ថាប័ននីមួយៗ ព្រមទាំង រដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវរៀបចំ។ ដោយឡែក ចំពោះការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងមានសារាចរណែនាំដោយឡែកមួយផ្សេងទៀតស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១។

ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍ដ៏សំខាន់សម្រាប់៖ (១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងគោលនយោបាយរបស់រាជរដ្ឋាភិបាល, (២)-បង្កើនវិចារណកម្មអាទិភាពចំណាយឱ្យកាន់តែឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន, (៣)-ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់

ក្រសួង-ស្ថាប័ន ដើម្បីសម្រេចគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ, (៤)-ជាមូលដ្ឋានសម្រាប់ពន្យល់ និងបង្ហាញសេចក្តីសំអាងអំពីតម្រូវការថវិកាសម្រាប់អនុវត្តគោលនយោបាយ និង (៥)-ជាមូលដ្ឋានសម្រាប់ការរៀបចំ និងវិភាជថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព។ ដូច្នេះ ផែនការយុទ្ធសាស្ត្រថវិកាត្រូវតែឆ្លុះបញ្ចាំងឱ្យឃើញច្បាស់អំពីគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័នសាមីនីមួយៗ, អំពីកម្មវិធី, អំពីសូចនាករ និងគោលដៅសូចនាករសម្រាប់វាស់វែងលទ្ធផលនៃការអនុវត្តកម្មវិធី សមស្របទៅនឹងទំហំថវិកា និងលទ្ធភាពថវិកាដែលមាន ដើម្បីរួមចំណែកសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ ក្រសួង-ស្ថាប័នមួយត្រូវមានផែនការយុទ្ធសាស្ត្រថវិការួមមួយដែលគ្របដណ្តប់ទាំងថវិការដ្ឋបាលកណ្តាល, ថវិកាមន្ទីរជំនាញរាជធានី-ខេត្ត និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមឱវាទក្រសួង-ស្ថាប័ននោះ ព្រមទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ(សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ)។

ទន្ទឹមនេះ ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍សំខាន់សម្រាប់ធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន ព្រមទាំងរវាងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីធ្វើឱ្យផែនការយុទ្ធសាស្ត្រថវិកាមានគុណភាពកាន់តែល្អប្រសើរ ក៏ដូចជាជួយលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជ និងគ្រប់គ្រងថវិកាប្រចាំឆ្នាំ។ ជាមួយគ្នានេះ, ក្រសួង-ស្ថាប័ននីមួយៗត្រូវយកចិត្តទុកដាក់កែលម្អគុណភាពផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ ដោយធានាការផ្សារភ្ជាប់ថវិកាទៅនឹងអាទិភាពគោលនយោបាយដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលអាណត្តិទី ៦ នៃរដ្ឋសភា ស្របតាមគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការណែនាំបន្ថែមតាមរយៈសារាចរណែនាំប្រចាំឆ្នាំនេះ។ ដូចនេះ *ក្រសួង-ស្ថាប័ននីមួយៗ ត្រូវជំរុញ និងលើកទឹកចិត្តដល់**ក្រុមការងារថវិកា**របស់ខ្លួនដែលមានសមាសភាពមកពីអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ឬ/និង ថវិកា/គណនេយ្យ ដែលហៅថា "**អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ**", អគ្គនាយកដ្ឋាន/នាយកដ្ឋានផែនការ, អង្គភាពថវិកា/អង្គភាពជំនាញ និងអង្គភាពគ្រប់គ្រងគម្រោងឱ្យដំណើរការដោយសកម្ម និងប្រកបដោយការទទួលខុសត្រូវខ្ពស់។* ដូចនេះ ក្រុមការងារថវិកាត្រូវខិតខំធានាឱ្យប្រាកដថា ទាំងធនធាន និងទាំងសកម្មភាពការងារទាំងអស់របស់ក្រសួង-ស្ថាប័នខ្លួន ត្រូវបានដាក់បញ្ចូល ឬឆ្លុះបញ្ចាំងក្នុងផែនការយុទ្ធសាស្ត្រថវិកា សំដៅធានាថាថវិកាត្រូវបានវិភាជត្រង់ទៅចំសកម្មភាព និងចំសេចក្តីត្រូវការយ៉ាងពិតប្រាកដរបស់អង្គភាពអនុវត្តសកម្មភាពរៀងខ្លួន ព្រមទាំងធានាបាននូវតុល្យភាពនៃការវិភាជថវិកា ហើយឆ្លើយតបបានជាអតិបរមាទៅនឹងគោលបំណងគោលនយោបាយ និងរវាងកម្មវិធីដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។ ដូចឆ្នាំកន្លងមកផងដែរ ក្រសួង-ស្ថាប័ននីមួយៗ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តល់កិច្ចសហការល្អរវាងគ្នាទៅវិញទៅមក ដោយអនុញ្ញាតឱ្យ**ក្រុមការងារថវិកា**តាមក្រសួង-ស្ថាប័នសាមីមានភាពជាម្ចាស់ក្នុងការធ្វើការងារជាមួយមន្ត្រីជំនាញថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**ដើម្បីពិនិត្យឡើងវិញ និងកែលម្អរចនាសម្ព័ន្ធកម្មវិធី និងសូចនាករសមិទ្ធកម្មតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធីនីមួយៗ** ក្នុងគោលបំណងដើម្បីបង្កើនគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក៏ដូចជាប្រសិទ្ធភាពក្នុងការរៀបចំច្បាប់ថវិកាប្រចាំឆ្នាំ។

ក្នុងគោលដៅបង្កើនគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា, ស្របតាមទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥, **ក្របខ័ណ្ឌថវិការយៈពេលមធ្យម** (ក.ថ.ម) ត្រូវបានដាក់អនុវត្ត

សាកល្បង ដើម្បីផ្តល់ជាកញ្ចប់ថវិកាក្នុងកម្រិតពិតានចំណាយគោលមួយដល់គ្រប់ក្រសួង-ស្ថាប័ន ដូចមានលម្អិតនៅក្នុង**ផ្នែក២.៣** សម្រាប់រៀបចំផែនការថវិកាមធ្យម ៣ ឆ្នាំរំកិល ទៅតាមរចនាសម្ព័ន្ធកម្មវិធី និងគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ ហើយដែលនឹងរួមចំណែកសម្រេចអាទិភាពគោលនយោបាយតាមវិស័យ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ក្នុងន័យនេះ ដើម្បីជួយដល់ក្រសួង-ស្ថាប័ន មានមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ ឱ្យកាន់តែមានភាពជាក់ស្តែង រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង-ស្ថាប័ន ដូចខាងក្រោម៖

## ២-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ បានផ្តល់ទស្សនៈវិស័យរយៈពេលមធ្យមនៃការអភិវឌ្ឍសេដ្ឋកិច្ច និងកំណត់អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងនិន្នាការចំណូល និងចំណាយថវិកាជាតិសម្រាប់រយៈពេលមធ្យម ២០២១-២០២៣ ក៏ដូចជាផ្តល់នូវលំហថវិការួមសម្រាប់គ្រប់ក្រសួង-ស្ថាប័ន កំណត់អាទិភាពសកម្មភាពការងារសម្រាប់រយៈពេលខ្លី និងមធ្យមរបស់ខ្លួន។ ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏កំណត់ផងដែរអំពីលទ្ធភាពផ្នែកធនធាន និងអាទិភាពគោលនយោបាយចម្បងៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ដូចនេះអាចនិយាយបានថា នៅក្នុងដំណើរការនៃការរៀបចំផែនការថវិកា ការកំណត់ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺជាយន្តការពីលើចុះក្រោម ចំណែកឯ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការពីក្រោមឡើងលើ។ យន្តការទាំងពីរនេះ គឺមានភាពចាំបាច់មិនអាចខ្វះបានដើម្បីធានាប្រសិទ្ធភាព និងភាពប្រាកដប្រជាអំពីលទ្ធភាពថវិកា និងការរៀបចំច្បាប់ថវិកាប្រចាំឆ្នាំ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលសូមគូសរំលេចនូវខ្លឹមសារស្នូលនៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានរៀបចំដូចខាងក្រោម៖

### ២.១-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

សេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំ ២០២០ ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនអវិជ្ជមាន ១,៩% ដែលជាអត្រាមិនធ្លាប់មានកន្លងមក, ដែលតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ កំណើនសេដ្ឋកិច្ចត្រូវបានគ្រោងសម្រេចបានក្នុងអត្រា ៦,៥%, ដោយសារការរីករាលដាលយ៉ាងលឿននៃជំងឺកូវីដ-១៩ ដែលបាននិងកំពុងធ្វើឱ្យតម្រូវការខាងក្រៅធ្លាក់ចុះយ៉ាងគំហុក និងរុញច្រានប្រទេសជាច្រើន ជាពិសេសបណ្តាប្រទេសដែលជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជាប្រឈមនឹងកំណើនអវិជ្ជមាន។ ទោះយ៉ាងនេះក្តី, តាមការព្យាករណ៍, កំណើនសេដ្ឋកិច្ចក្នុងឆ្នាំ ២០២១ ត្រូវបានរំពឹងថាអាចនឹងងើបឡើងវិញមកក្នុងអត្រាកំណើន ៣,៥% ដោយសារការរំពឹងទុកនៃការងើបឡើងវិញយឺតនៃសកម្មភាពសេដ្ឋកិច្ច ជាពិសេសការកើនឡើងក្នុងកម្រិតទាបនៃតម្រូវការខាងក្រៅ និងទំនុកចិត្តទីផ្សារក្នុងស្រុក ។ កំណើននេះ ត្រូវបានគាំទ្រដោយកំណើននៃវិស័យកសិកម្មប្រមាណ ១,៦% និងការងើបឡើងវិញនៃវិស័យឧស្សាហកម្មដែលអាចសម្រេចបានកំណើនក្នុងអត្រា ៤,១% ដោយសារការកើនឡើងវិញ

ក្នុងកម្រិតទាបនៃអនុវិស័យកាត់ដេរ និងអនុវិស័យសំណង់ ខណៈដែលអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរនៅតែបន្តកំណើនល្អប្រសើរ, ព្រមទាំងការកើនឡើងវិញនៃវិស័យសេវាកម្មមកក្នុងអត្រាកំណើនទាប ៣,៦% ដោយសារការរំពឹងទុកការងើបឡើងវិញក្នុងកម្រិតទាបនូវសកម្មភាពសេដ្ឋកិច្ច ជាពិសេស ក្នុងវិស័យទេសចរណ៍ និងការប្រើប្រាស់ក្នុងស្រុក បន្ទាប់ពីវិបត្តិកូវីដ-១៩។

អត្រាអតិផរណា ត្រូវបានព្យាករថានឹងស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានក្នុងអត្រា ២,៨% ក្នុងឆ្នាំ ២០២០ ដោយសារការរំពឹងទុកការកើនឡើងនៃតម្រូវការ (demand shock) ម្ហូបអាហារ និងផលិតផលផ្សេងទៀតនៅលើទីផ្សារ ស្របពេលដែលការផ្គត់ផ្គង់ត្រូវបានរំពឹងថានឹងថមថយ ខណៈដែលថ្លៃដឹកជញ្ជូនត្រូវបានប៉ាន់ស្មានថានឹងធ្លាក់ចុះទៅតាមនិន្នាការថ្លៃប្រេងលើទីផ្សារអន្តរជាតិ។ ក្នុងឆ្នាំ ២០២១ អត្រានេះត្រូវបានព្យាករថានឹងស្ថិតក្នុងអត្រា ៣,១% ដោយសារការរំពឹងទុកការកើនឡើងបន្តិចមកវិញនូវថ្លៃប្រេងអន្តរជាតិ។

អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ត្រូវបានរំពឹងថានឹងមានស្ថិរភាពក្នុងឆ្នាំ ២០២០ និង ២០២១ គឺស្ថិតក្នុងរង្វង់ ៤១០០ រៀលក្នុងមួយដុល្លារអាមេរិក ដោយសារជំនឿទុកចិត្តពីសំណាក់សាធារណជនលើការប្រើប្រាស់ប្រាក់រៀល តាមរយៈការអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា និងការបន្តពង្រឹងគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ។

ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានប៉ាន់ស្មានថានឹងកើនឡើងដល់ទំហំ ១៧,៦% នៃ ផសស ក្នុងឆ្នាំ ២០២០ ដោយសារការរំពឹងទុកការធ្លាក់ចុះនៃការនាំចេញ និងការធ្លាក់ចុះនៃចំណូលជារូបិយប័ណ្ណ ដែលបានមកពីទេសចរអន្តរជាតិ មានល្បឿនលឿនជាងការធ្លាក់ចុះនៃ ផសស។ យ៉ាងណាមិញ, ទំហំនេះត្រូវបានព្យាករថានឹងរួមតូចបន្តិចមកត្រឹម ១៧,៣% នៃ ផសស ក្នុងឆ្នាំ ២០២១ ដោយសារការរំពឹងទុកនៃការងើបឡើងវិញបន្តិចនូវការនាំចេញ និងវិស័យទេសចរណ៍។ ទុនបម្រុងអន្តរជាតិសរុបក្នុងឆ្នាំ ២០២០ ត្រូវបានរំពឹងថានឹងថយចុះមកត្រឹម ១៦ ៩៣៧ លានដុល្លារអាមេរិក ដោយសារការរីកធំនៃឱនភាពគណនីចរន្ត រួមផ្សំនឹងការរំពឹងទុកការធ្លាក់ចុះលំហូរទុនវិនិយោគពីបរទេស។ ទោះជាយ៉ាងនេះក្តី, ទំហំនេះនៅតែអាចធានាការនាំចូលបាន ៨,៥ ខែ ដោយហេតុថាការនាំចូលរបស់កម្ពុជាក៏នឹងត្រូវថមថយផងដែរ។ ក្នុងឆ្នាំ ២០២១ ទុនបម្រុងអន្តរជាតិសរុប ត្រូវបានព្យាករថានឹងកើនឡើង ១៦ ៩៨១ លានដុល្លារអាមេរិក និងធានាការនាំចូលបាន ៨ ខែ។

## ២.២-ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២១ ដែលរៀបចំដោយឈរលើមូលដ្ឋាននៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដូចបានគូសបញ្ជាក់ខាងលើ និង "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤**" មានគោលបំណង ដូចតទៅ៖

- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ;
- បន្តក្សាលំនឹង និងជំរុញកំណើនសេដ្ឋកិច្ច ក្នុងបរិការណ៍នៃជំងឺកូវីដ-១៩ តាមរយៈការជំរុញការនាំចេញឱ្យអស់ពីសក្តានុពល និងងាកពីការពឹងផ្អែកទាំងស្រុងលើតម្រូវការខាងក្រៅ មកពឹងផ្អែកមួយចំនួនលើតម្រូវការក្នុងស្រុក;
- បន្តធានានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម ប្រកបដោយបរិយាប័ន្ន;

- បន្តអនុវត្តក្របខ័ណ្ឌចំណាយអន្តរាគមន៍ ដើម្បីដោះស្រាយបញ្ហាប្រឈមនានាចំពោះមុខ និងហានិភ័យនានា ប្រកបដោយប្រសិទ្ធភាពទាំងក្នុងកម្រិតវិភាជន៍ និងប្រតិបត្តិការ;
- ជំរុញការអនុវត្ត "ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥";
- គាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌; ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ;
- បង្កើនប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥;
- បន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០១៩-២០២៣ ប្រកបដោយប្រសិទ្ធភាពខ្ពស់សំដៅធានាបាននូវចីរភាពបំណុល;
- ពន្លឿនការអនុវត្តឱ្យបានខ្លាំងក្លានូវវិធានការនៃ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥" តាមរយៈការបន្តគាំទ្រការអភិវឌ្ឍវិស័យឯកជន និងសហគ្រាសធុនតូច និងមធ្យម ជាមួយនឹងវិធានការជាក់លាក់ និងការបន្តវិនិយោគសាធារណៈលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តលើការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន, ថាមពល និងឌីជីថល;
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ទាំងកម្រិតទាប មធ្យម និងខ្ពស់ ព្រមទាំងសុខុមាលភាពសង្គម ដើម្បី ផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ ឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការទីផ្សារ;
- ជំរុញការធ្វើពិពិធកម្មផលិតផល, គោលដៅ និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និង
- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ដោយផ្តោតលើការបង្កើនផលិតភាព, ពិពិធកម្ម, ការកែច្នៃកសិផល និងពាណិជ្ជូបនីយកម្ម។

ដើម្បីសម្រេចបានតាមគោលដៅនៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើ រាជរដ្ឋាភិបាលបានកំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ ២០២១ ដូចខាងក្រោម៖

- **ចំណូលក្នុងស្រុកសរុបសម្រាប់ឆ្នាំ** ២០២១ ត្រូវគ្រោងសម្រេចឱ្យបាន ១៨,៣៥% នៃ ផសស ក្នុងនោះចំណូលចរន្តក្នុងទំហំ ១៨,១៧% នៃ ផសស និងចំណូលមូលធនក្នុងទំហំ ០,១៩% នៃ ផសស។ ចំណូលចរន្តត្រូវបានគ្រោងថយចុះ ១៨,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២០ ដែលក្នុងនោះថ្នាក់ជាតិត្រូវសម្រេចឱ្យបានប្រមាណ ១៧,០៩% នៃ ផសស និងសម្រាប់ថ្នាក់ក្រោមជាតិ ១,០៨% នៃ ផសស។ ដោយឡែក ការប្រមូលចំណូលពីអគ្គនាយកដ្ឋានពន្ធដារ ត្រូវគ្រោងសម្រេចឱ្យបាន ៧,៦៩% នៃ ផសស, ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវគ្រោងសម្រេចឱ្យបាន ៨,០៥% នៃ ផសស និងចំណូលមិនមែនសារពើពន្ធត្រូវគ្រោងសម្រេចឱ្យបាន ២,៤២% នៃ ផសស។
- **ចំណាយសរុបថវិការដ្ឋនៅឆ្នាំ** ២០២១ នឹងកំណត់ក្នុងរង្វង់ ២៥,០៧% នៃ ផសស ក្នុងនោះ ចំណាយសរុបថវិកាថ្នាក់ជាតិ ២៣,៩៩% នៃ ផសស និងចំណាយសរុបថវិកាថ្នាក់ក្រោមជាតិ ១,៩៤% នៃ ផសស

ដោយរួមបញ្ចូលទាំងការឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិចំនួន ០,៨៦% នៃ ផសស។ ចំណាយចរន្តថវិការដ្ឋត្រូវកំណត់ក្នុងកម្រិត ១៥,៩៤% នៃ ផសស ដែលក្នុងនោះ៖

- **ចំណាយបន្ទុកបុគ្គលិក** មានសមាមាត្រស្មើនឹង ៤៨,៦១% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៧,៧៥% នៃ ផសស។
- **ចំណាយក្រៅបន្ទុកបុគ្គលិក** មានសមាមាត្រស្មើនឹង ៥១,៣៩% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៨,១៩% នៃ ផសស ដោយផ្តោតលើតម្រូវការចំណាយសម្រាប់ទ្រទ្រង់ដល់ដំណើរការការងារ និងការអនុវត្តគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជា ការការពារនិងទប់ទល់នឹងជំងឺកូវីដ-១៩, ការសម្របខ្លួនទៅនឹងបរិការណ៍ថ្មី, ការអនុវត្តក្របខ័ណ្ឌគោល-នយោបាយជាតិគាំពារសង្គមជាដើម។

ទន្ទឹមនេះ សម្រាប់ឆ្នាំ ២០២១ ចំណាយមូលធនត្រូវបានគ្រោងបង្កើនដល់ប្រមាណជា ៩,១៣% នៃ ផសស ក្នុងគោលដៅស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ជួយទ្រទ្រង់ផលិតភាពក្នុងសេដ្ឋកិច្ច និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។

**សរុបចំណាយថវិកាថ្នាក់ជាតិ** ដែលរួមបញ្ចូលទាំងហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងវិភាជទៅតាមវិស័យដូចខាងក្រោម៖

- **វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងប្រមាណ ១,៩៩% នៃ ផសស ថយចុះ ៦,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២០ ដោយផ្តោតលើការបន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ និងការលើកកម្ពស់សមត្ថភាពស្ថាប័ន;
- **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងប្រមាណ ៣,៨៩% នៃ ផសស ថយចុះ ៤,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២០ ដោយផ្តោតលើការបន្តយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ និងការបំពាក់មធ្យោបាយ និងបរិក្ខារចាំបាច់នានា ក្នុងបុព្វហេតុធានាកិច្ចការពារជាតិ និងរក្សាសន្តិភាព និងស្ថិរភាពនយោបាយ;
- **វិស័យសង្គមកិច្ច** ត្រូវបានគ្រោងប្រមាណ ៦,១៤% នៃ ផសស ថយចុះ ១១,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២០ សំដៅបន្តគាំទ្រដល់ការលើកកម្ពស់គុណភាព និងពង្រីកការទទួលបានសេវាសុខាភិបាល ក៏ដូចជាសុខុមាលភាពសង្គម តាមរយៈការគាំទ្រដល់កម្មវិធីមូលនិធិសមធម៌ និងការបន្តគាំទ្រដល់ការអនុវត្តគោលនយោបាយជាតិគាំពារសង្គម ជាពិសេសក្នុងបរិការណ៍ជំងឺកូវីដ-១៩។ ជាមួយគ្នានេះ បន្តការយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ទាំងកម្រិតទាប មធ្យម និងខ្ពស់; និង
- **វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងប្រមាណ ៦,៤២% នៃ ផសស ថយចុះ ៥,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២០ ដោយផ្តោតលើការបន្តធានាការអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន និងការបែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ក្នុងសង្គម ក្នុងនោះ ការបន្តពន្លឿនការធ្វើ-ពិពិធកម្មសេដ្ឋកិច្ច និងបង្កើនភាពប្រកួតប្រជែង ដោយផ្តោតលើការគាំទ្រការអភិវឌ្ឍវិស័យឯកជន

និងការបន្តវិនិយោគសាធារណៈ លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន ថាមពល និងឌីជីថល ដើម្បីជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ក្នុងបរិការណ៍វិបត្តិជំងឺកូវីដ-១៩;

- ចំពោះកញ្ចប់ថវិកាសម្រាប់អន្តរាគមន៍លើផលប៉ះពាល់ពីជំងឺកូវីដ-១៩ រួមមាន ការផ្តល់ការបណ្តុះ-បណ្តាលជំនាញវិជ្ជាជីវៈដល់កម្មករ ការផ្តល់ការឧបត្ថម្ភដល់កម្មករក្នុងពេលពោងចក្រព្យួរការងារ កម្មវិធីសាច់ប្រាក់ពលកម្ម និងការផ្តល់ជំនួយសង្គមដល់ប្រជាពលរដ្ឋងាយរងគ្រោះជាដើម ត្រូវបានគ្រោងដោយឡែកក្នុងក្របខ័ណ្ឌនៃចំណាយមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល ដើម្បីរៀបចំជាគម្រោងសម្រាប់អនុវត្តនៅក្នុងផ្នែកចំណាយមូលធន។

ដូចនេះ ដោយឈរលើមូលដ្ឋានក្របខ័ណ្ឌចំណូល និងចំណាយខាងលើ, អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ ២០២១ នឹងសម្រេចបានប្រមាណ ២,២៣% នៃ ផសស និងឱនភាពថវិកាសរុបនឹងត្រូវឡើងដល់ -៦,៧២% នៃ ផសស។ ក្នុងក្របខ័ណ្ឌនេះ ថវិកាឆ្នាំ ២០២១ មានចរិតជាការពង្រឹងវិន័យ និងប្រសិទ្ធភាពថវិកា តាមរយៈការរក្សាសមតុល្យថវិកា និងការផ្តោតកាន់តែសំខាន់លើប្រសិទ្ធភាពចំណាយ ទាំងកម្រិតវិភាជ និងប្រតិបត្តិការ។

ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ, ការគ្រោងថវិកាឆ្នាំ ២០២១ និងឆ្នាំបន្តបន្ទាប់ ត្រូវរៀបចំឡើងឈរលើមូលដ្ឋានយុទ្ធសាស្ត្រ និងក្របខ័ណ្ឌនៃវិធានការ ដូចខាងក្រោម៖

### ក. វិធានការផ្នែកចំណូល

### ក.១-វិធានការផ្នែកចំណូលពន្ធដារ

វិធានការគន្លឹះដាក់លាក់សម្រាប់អនុវត្តក្នុងឆ្នាំ ២០២១ ក្នុងទិសដៅរក្សាចីរភាពកំណើនចំណូលពន្ធដារ និងឆ្លើយតបទៅនឹងបញ្ហាប្រឈមក្រោយពេលវិបត្តិជំងឺកូវីដ-១៩ រួមមាន៖

- *ការបន្តពង្រឹងមុខងារប្រតិបត្តិការស្នូល រួមមាន ការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្តល់សេវាអ្នកជាប់ពន្ធ, ការ-ចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការស៊ើបអង្កេត, ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា ដោយ៖*
  - បន្តកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យចុះបញ្ជីពន្ធដារ ដើម្បីសម្រួលដល់អ្នកជាប់ពន្ធក្នុងការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស និងរៀបចំយន្តការនៃការចុះបញ្ជីពន្ធដារតាមប្រព័ន្ធស្វ័យប្រវត្តិកម្មជាមួយក្រសួង-ស្ថាប័នផ្សេងៗ;
  - អនុវត្តការចុះបញ្ជីបែបអេឡិចត្រូនិក (e-registration), ការដាក់លិខិតប្រកាសពន្ធបែបអេឡិចត្រូនិក (e-filing), និងការបង់ប្រាក់ពន្ធបែបអេឡិចត្រូនិក (e-payment) ដែលមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡា;
  - ជំរុញការផ្តល់សេវាចុះបញ្ជីឱ្យបានទាន់ពេលវេលា ស្របតាមកម្រងសេវាសាធារណៈ និងសម្រេចគោលដៅនៃការចុះបញ្ជីឱ្យបាន ២០% ក្នុងមួយឆ្នាំ;
  - ជំរុញការចុះបញ្ជីអចលនទ្រព្យនៅរាជធានីភ្នំពេញ ឱ្យបានពេញលេញតាមទិន្នន័យដែលបានអង្កេតក្នុងឆ្នាំ ២០២០ និងបញ្ចប់ការធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យនៅតាមបណ្តាខេត្តដែលមានសក្តានុពល ក្នុងឆ្នាំ ២០២១;

- បង្កើនការបញ្ជ្រាបវប្បធម៌នៃការបង់ពន្ធ, ច្បាប់, បទប្បញ្ញត្តិ និងកាតព្វកិច្ចពន្ធដារឱ្យកាន់តែទូលំទូលាយ ដល់សាធារណៈជន តាមរយៈការបង្កើនការផ្សព្វផ្សាយតាមបណ្តាញសារព័ត៌មាន, ការរៀបចំវគ្គ-បណ្តុះបណ្តាល សិក្ខាសាលា និងវេទិកាពិគ្រោះយោបល់;
- ពង្រឹង និងពន្លឿនយន្តការបង្វិលសងអាករលើតម្លៃបន្ថែម តាមរយៈការបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធផ្ទៀងផ្ទាត់ដោយស្វ័យប្រវត្តិ និងបន្តធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ e-filing និង e-payment;
- បន្តបង្កើនការប្រមូលទិន្នន័យផ្តុំព័ត៌មានពីគ្រប់ប្រភព និងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គភាពពាក់ព័ន្ធ តាមរយៈយន្តការផ្លាស់ប្តូរព័ត៌មាន ក្នុងគោលដៅកសាងកម្មវិធីសវនកម្មប្រចាំឆ្នាំ និងពង្រឹងការធ្វើសវនកម្មតាមវិស័យដែលមានហានិភ័យខ្ពស់;
- បង្កើតប្រព័ន្ធស្វ័យប្រវត្តិកម្មលើការកំណត់ហានិភ័យអ្នកជាប់ពន្ធ ដោយផ្អែកលើសៀវភៅណែនាំស្តីពីវិធីសាស្ត្រក្នុងការកំណត់ហានិភ័យអ្នកជាប់ពន្ធ និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធដើម្បីចាត់វិធានការលើបទល្មើសពន្ធដារ;
- ពង្រឹងយុទ្ធសាស្ត្រគ្រប់គ្រងបំណុលពន្ធ សំដៅកាត់បន្ថយជាអតិបរមានូវបំណុលបច្ចុប្បន្ន និងចៀសវាងការកើនឡើងបំណុលពន្ធអនាគត ជាពិសេសពង្រឹងការតឹងទារបំណុលចំពោះអាជីវកម្មដែលមិនទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងអាជីវកម្មដែលមានសក្តានុពល តាមរយៈការរៀបចំកម្មវិធីលើកទឹកចិត្តឱ្យអ្នកជាប់ជំពាក់បំណុលមកបង់បានលឿនជាងកាលកំណត់ ឬបន្ធូរបន្ថយឱ្យបង់ជាដំណាក់កាល;
- បន្តអនុវត្តវិធានការពាក់ព័ន្ធដែលបានដាក់ចេញ នៅក្នុងក្របខ័ណ្ឌគោលនយោបាយទំនើបកម្មប្រព័ន្ធពន្ធដារឆ្នាំ ២០១៩-២០២៣ ដែលផ្អែកលើគោលការណ៍អនុគ្រោះដល់កំណើន និងធានាយុត្តិធម៌, សមធម៌, សេវាល្អ, អភិបាលកិច្ចល្អ និងបង្កើនអនុលោមភាព។

- *ការបន្តពង្រឹងមុខងារគាំទ្រ ដោយ ៖*
  - គិតគូរដាក់ចេញនូវវិធានការគោលនយោបាយអនុគ្រោះ ឬបន្ធូរបន្ថយផ្នែកពន្ធដារ និងការសម្រួលនីតិវិធីរដ្ឋបាលសារពើពន្ធមួយចំនួន ដើម្បីជួយដល់អាជីវកម្មក្នុងស្រុក និងធុរកិច្ចអាចបន្តសកម្មភាពរបស់ខ្លួន និងជួយដល់ការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច;
  - បន្តកិច្ចការរៀបចំបទប្បញ្ញត្តិស្តីពីពន្ធដារ ដើម្បីសម្រួលដល់ការវិនិយោគ និងការប្រកបអាជីវកម្មរបស់អាជីវករ;
  - ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការវិភាគទិន្នន័យ ដើម្បីបង្កើនសមត្ថភាពធ្វើសវនកម្មសំដៅបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងហានិភ័យ;
  - សិក្សា និងពិនិត្យលទ្ធភាព ដើម្បីឈានបង្កើតឱ្យមានមជ្ឈមណ្ឌលរក្សាទិន្នន័យរួម (Big Data) និងចូលរួមជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធច្រកចេញចូលតែមួយនៃប្រព័ន្ធ National international Gateway និងប្រព័ន្ធទូទាត់ (Payment Gateway)។

## ក.២-វិធានការផ្នែកចំណូលគយ និងរដ្ឋាករ

វិធានការគន្លឹះ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តឆ្នាំ ២០២១ ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (អ.គ.រ.)

មាន ២ ផ្នែក និងផ្តោតលើគោលដៅជាអាទិភាព ដូចខាងក្រោម៖

- *ការបន្តពង្រឹងរដ្ឋបាលគយ និងកិច្ចសម្រួលពាណិជ្ជកម្ម ដោយ៖*
  - បន្តកែលម្អប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ ដើម្បីជំរុញការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ដំណាក់កាលទី ៣, ប្រព័ន្ធគ្រប់គ្រងហានិភ័យគយ ដោយរៀបចំប្រព័ន្ធទទួលព័ត៌មានជាមុន និង អនុវត្តយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ;
  - បន្តពង្រីកវិសាលភាព និងពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កេន និងប្រព័ន្ធកាមេរ៉ាសុវត្ថិភាព;
  - បន្តអនុវត្តការសម្រួលការបញ្ចេញទំនិញពីគយសម្រាប់វត្ថុធាតុដើម និងផលិតផលនាំចេញក្នុងវិស័យ ដែលទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងវិស័យអាទិភាពនានា;
  - កែសម្រួល និងដាក់ឱ្យអនុវត្តកញ្ចប់ប្រព្រឹត្តកម្មលើកទឹកចិត្តដល់ធុរជនដែលមានអនុលោមភាពខ្ពស់ តាមរយៈការផ្តល់ប្រព្រឹត្តកម្មពិសេសក្នុងការបំពេញបែបបទគយ និងបន្តពិនិត្យលទ្ធភាពបង្កើន ចំនួនធុរជនល្អបំផុត និង
  - បន្តពង្រឹងប្រសិទ្ធភាពការងារបច្ចេកទេសគយ (ការងារតម្លៃគិតពន្ធគយ, ការងារចំណាត់ថ្នាក់ទំនិញ និងការងារវិធានដើមកំណើតទំនិញ), ការអនុវត្តនីតិវិធីគយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។
- *ការបន្តពង្រឹងគោលនយោបាយពន្ធគយ និងអភិបាលកិច្ច ដោយ៖*
  - បន្តចូលរួមអនុវត្តគោលនយោបាយលើកទឹកចិត្តវិស័យអាទិភាព ដូចជា វិស័យកសិកម្ម, កម្មន្តសាល និងសហគ្រាសធុនតូច និងមធ្យម តាមរយៈ ១).ការពិនិត្យរកមុខទំនិញដើម្បីបញ្ចុះអត្រាពន្ធអាករ នាំចូល, និង ២).ការលើកសំណើទៅក្រុមការងារតារាងពន្ធគយអាស៊ាន (AHTN task force) ក្នុងការញែកលេខកូដចំពោះបន្ទាត់ពន្ធណាដែលមានមុខទំនិញបម្រើច្រើនវិស័យ ដើម្បីជាមូលដ្ឋាន អាចកំណត់អត្រាពន្ធគយខុសគ្នាឱ្យស្របតាមវិស័យនីមួយៗ;
  - ពង្រឹងការអនុវត្តគោលការណ៍លើកទឹកចិត្តពន្ធ និងអាករសម្រាប់គ្រប់វិស័យ និងមុខសញ្ញា ដែលទទួលបានការអនុគ្រោះ;
  - បន្តធ្វើការវាយតម្លៃផលប៉ះពាល់លើ ១.)ចំណូលពន្ធគយ ដែលបាត់បង់ពីការអនុវត្តកិច្ចព្រមព្រៀង ពាណិជ្ជកម្មសេរីនានា, ២.)ការកើនឡើងនូវផលិតផលក្នុងស្រុកជំនួសការនាំចូល និង ៣.)ការ-អនុវត្តគោលនយោបាយទម្លាក់ថ្លៃអគ្គិសនី និងការប្រើប្រាស់ថាមពលពីប្រភពមិនមែនប្រេងឥន្ធនៈ;
  - ពិនិត្យលទ្ធភាពកែសម្រួលមូលដ្ឋានគិតពន្ធ និងអត្រាអាករពិសេសលើទំនិញដែលមានលក្ខណៈ ប្រណិត, ប៉ះពាល់បរិស្ថាន និងសុខភាព ដើម្បីប៉ះប៉ូវការបាត់បង់ចំណូលក្នុងករណីចាំបាច់;
  - បន្តអនុវត្តយុទ្ធសាស្ត្រគយស្តីពីអនុលោមភាព និងការអនុវត្តច្បាប់ (enforcement strategy) ក្នុងនោះ រួមទាំងការចុះឃ្លាំមើលតំបន់ភូមិសាស្ត្រដែលមានហានិភ័យខ្ពស់, ការចែករំលែកព័ត៌មានពាក់ព័ន្ធ បទល្មើសគយក្នុងកម្រិតទ្វេភាគី តំបន់ និងសកល, និងការចូលរួមគម្រោងប្រតិបត្តិការគយរួមគ្នា;

- បន្តលើកកម្ពស់អនុលោមភាព និងការអនុវត្តច្បាប់របស់ធុរជន តាមរយៈការផ្សព្វផ្សាយច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធ ដើម្បីបង្កើនការយល់ដឹងអំពីតម្លៃនៃវប្បធម៌សារពើពន្ធស្អាតស្អំ និងផលវិបាកនៃអំពើល្មើស និងអំពើរត់ពន្ធ និង;
- រៀបចំផែនការដាក់លាក់ក្នុងការរៀបចំធនធានមនុស្សតាមអង្គភាពនៅគ្រប់កម្រិត ដើម្បីឆ្លើយតបនឹងតម្រូវការ ក៏ដូចជាការត្រៀមខ្លួនសម្រាប់ការវិវត្តនៃបច្ចេកវិទ្យាថ្មី និងការឈានឆ្ពោះទៅសម្រេចបាននូវអង្គភាពមួយដែលទំនើប។

**ក.៣-វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ**

ក្នុងទិសដៅបន្តកំណើនចំណូល និងពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងប្រភពចំណូលសក្តានុពល បន្ថែមលើវឌ្ឍនភាពសម្រេចបានកន្លងមក ក៏ដូចជាឆ្លើយតបនឹងបញ្ហាប្រឈមផ្សេងៗដែលអាចនឹងកើតមានឡើងក្នុងឆ្នាំ ២០២១ វិធានការគន្លឹះចាំបាច់ត្រូវបន្តអនុវត្ត រួមមានៈ

- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ឱ្យរឹតតែទូលំទូលាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ, បន្តធ្វើបច្ចុប្បន្នភាព និងដាក់បញ្ចូលកិច្ចសន្យា កិច្ចព្រមព្រៀង ឬអាជ្ញាបណ្ណ និងបន្តជំរុញការតភ្ជាប់ និងសន្ទានកម្មរវាង NRMIS និង FMIS ឱ្យបានពេញលេញ;
- បន្តអភិវឌ្ឍមុខងារប្រព័ន្ធ NRMIS បន្ថែមដូចជាការផ្តល់វិក្កយបត្រតាមអនឡាញ និងការបង់ចំណូលមិនមែនសារពើពន្ធតាមរយៈការទូទាត់បែបអេឡិចត្រូនិក (E-payment) ដើម្បីលើកកម្ពស់ស្តង់ដារសេវាសម្រាប់បង់ចំណូលឱ្យមានភាពងាយស្រួល និងតម្លាភាព;
- បន្តពង្រឹងការអនុវត្តប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ក្នុងប្រព័ន្ធក្រៅបណ្តាញ (offline) ដោយជំរុញការរៀបចំបញ្ជីក្នុងប្រព័ន្ធ និងការរៀបចំប័ណ្ណកម្មសិទ្ធិឱ្យបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ដើម្បីឈានដល់ការតភ្ជាប់ប្រព័ន្ធ SARMIS ជាមួយប្រព័ន្ធគ្រប់គ្រងទិន្នន័យដទៃទៀត (online);
- បង្កើនសមត្ថភាពចរចាជាមួយភាគីពាក់ព័ន្ធ និងរៀបចំយន្តការគ្រប់គ្រងប្រភពចំណូល ដែលមានសក្តានុពលក្នុងវិស័យរ៉ែ និងថាមពល ដូចជាចំណូលពីសម្បទាន និងចំណូលពីការបែងចែកផលឱ្យមានប្រសិទ្ធភាព;
- ជំរុញការសិក្សា និងពិនិត្យលទ្ធភាពអភិវឌ្ឍន៍រមណីយដ្ឋានដែលមានសក្តានុពលថ្មីៗទាក់ទាញភ្ញៀវទេសចរ ដើម្បីបង្កើនទិសដៅទេសចរណ៍នៅកម្ពុជា;
- អនុវត្តយន្តការកំណត់ និងបង់កម្រៃសេវា រួមមានកម្រៃលេខទូរគមនាគមន៍, កម្រៃពីហ្រ្វេកង់ និងជំរុញការកែប្រែឡើងវិញនូវកម្រៃអាជ្ញាបណ្ណឱ្យបានសមស្រប និងគ្រប់ជ្រុងជ្រោយ តាមបទដ្ឋានជាធរមាន;
- បន្តជំរុញការប្រើប្រាស់ទិន្នន័យពីមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យទូរគមនាគមន៍ (DMC) ជាមូលដ្ឋានក្នុងការកំណត់ការបែងចែកប្រាក់ចំណូល និងសម្រាប់ផ្ទៀងផ្ទាត់ជាមួយចំណូលសារពើពន្ធ;

- បន្តពង្រឹងការអនុវត្តប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីការគ្រប់គ្រងចំណូលពីកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋានឱ្យមានប្រសិទ្ធភាព និងជំរុញការអនុវត្តកាតព្វកិច្ចបង់ចំណូលតាមកិច្ចសន្យាជួលឱ្យបានពេញលេញ;
- ត្រៀមអនុវត្តគោលការណ៍រួម ស្របតាមតម្លៃទីផ្សារក្នុងការកៀរគរចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ និងពន្លឿនកិច្ចការត្រួតពិនិត្យលើការអនុវត្តកិច្ចសន្យាជួលឱ្យបានរហ័ស;
- បន្តពន្លឿននីតិវិធីរៀបចំឡើងវិញនូវកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច និងពង្រឹងកិច្ចសហប្រតិបត្តិការ រវាងក្រសួង-ស្ថាប័នពាក់ព័ន្ធឱ្យកាន់តែមានប្រសិទ្ធភាព ខណៈបន្តការប្រមូលចំណូលពីដីសម្បទាន សេដ្ឋកិច្ច ឱ្យអស់សក្តានុពលដោយផ្អែកលើគោលការណ៍ និងបទប្បញ្ញត្តិជាធរមាន;
- ដាក់ឱ្យប្រើប្រាស់ឯកសារគោល (Blueprint) ស្តីពីការកែទម្រង់ប្រព័ន្ធចំណូលមិនមែនសារពើពន្ធ និងជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និង ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ;
- ដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាសម្រាប់ចាត់ចែងលើទ្រព្យសម្បត្តិ ដែលបាន រឹបអូស;
- ពន្លឿនការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម និងរៀបចំលិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិគាំទ្រដល់ច្បាប់
- ពន្លឿនការរៀបចំនូវក្របខ័ណ្ឌគតិយុត្តថ្មីស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ ឱ្យស្របតាម ការវិវឌ្ឍនៃសកម្មភាពសេដ្ឋកិច្ចកម្ពុជាជាក់ស្តែង;
- បង្កើនកិច្ចសហការរវាងថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលតាមក្រសួង-ស្ថាប័ន ដែលទទួលខុសត្រូវ អនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រកៀរគរចំណូល ដោយតាមដាន និងរាយការណ៍ជាប្រចាំ;
- ពង្រឹងប្រសិទ្ធភាព នៃដំណើរការរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែន-សារពើពន្ធ ដើម្បីធ្វើការតាមដាន និងរៀបចំរបាយការណ៍បូកសរុបជូនប្រមុខរាជរដ្ឋាភិបាលស្តីពី ស្ថានភាពនៃការប្រមូលចំណូលរបស់ក្រសួង-ស្ថាប័ននៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**ខ. វិធានការផ្នែកចំណាយ**

ក្នុងក្របខ័ណ្ឌនៃគោលដៅរក្សាលំនឹងសេដ្ឋកិច្ច និងទ្រទ្រង់កំណើនសេដ្ឋកិច្ចឡើងវិញ, រាជរដ្ឋាភិបាល ចាំបាច់ត្រូវអនុវត្តវិធានការដាក់លាក់ និងមុតស្រួច ដើម្បីបង្កើនប្រសិទ្ធភាពចំណាយក្នុងឆ្នាំ ២០២១ ដូច ខាងក្រោម ៖

- ត្រៀមកញ្ចប់ថវិកាសម្រាប់ដោះស្រាយតម្រូវការបន្ទាន់ និងចាំបាច់ភ្លាមៗ ក្នុងវិបត្តិជំងឺកូវីដ-១៩ ដើម្បី ទ្រទ្រង់សកម្មភាពសេដ្ឋកិច្ច និងជួយគាំទ្រទាន់ពេលវេលាលើកម្មវិធីសំណាញ់សុវត្ថិភាពដល់ក្រុមអ្នក ងាយរងគ្រោះ និងរក្សាលំនឹងការងារជូនប្រជាពលរដ្ឋដែលប៉ះពាល់ពីវិបត្តិនេះ;
- រក្សាកម្រិតប្រាក់បៀវត្ស (បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារ) របស់មន្ត្រីរាជការ ស្មើនឹងកម្រិត ដែលទទួលបានក្នុងច្បាប់ថវិកាឆ្នាំ ២០២០។ លើសពីនេះ គ្រប់ក្រសួង-ស្ថាប័នទាំងអស់ត្រូវអនុវត្តឱ្យ

បានម៉ឺងម៉ាត់នូវគោលការណ៍ជាធរមាន ក្នុងការជ្រើសរើសក្របខ័ណ្ឌមន្ត្រីថ្មីឱ្យស្មើត្រឹមនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍;

- បន្តកែលម្អគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃផែនការយុទ្ធសាស្ត្រថវិកា ដោយពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយតាមវិស័យអាទិភាព;
- បន្តពង្រឹងការផ្សារភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងសំណើថវិកាប្រចាំឆ្នាំ;
- បន្តអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញពាក់ព័ន្ធ និងធនធានមនុស្ស;
- បន្តពង្រឹងការអនុវត្តថវិកាកម្មវិធីនៅគ្រប់ក្រសួង-ស្ថាប័ន និងពង្រឹងគុណភាពព័ត៌មានសមិទ្ធកម្ម ដើម្បីឈានទៅចាប់ផ្ដើមអនុវត្តថវិកាសមិទ្ធកម្ម តាមរយៈការអនុវត្តកិច្ចព្រមព្រៀងលើលទ្ធផលក្នុងឆ្នាំ និងការរៀបចំយន្តការសម្រាប់ធ្វើការវាយតម្លៃ និងការផ្ដល់ព័ត៌មានពីសមិទ្ធកម្ម;
- ពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធ FMIS ដល់គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយចាប់ផ្ដើមអនុវត្តស្វ័យប្រវត្តិកម្មចំណាយ និងដាក់អនុវត្តចំណាត់ថ្នាក់ថវិកាទាំង ៧;
- បន្តរឹតត្បិតលើចំណាយមិនចាំបាច់ និងការមិនអនុញ្ញាតឱ្យក្រសួង-ស្ថាប័នណាមួយ ចាយលើសពីឥណទានដែលអនុញ្ញាតដោយច្បាប់ថវិកាប្រចាំឆ្នាំ;
- បន្តពង្រឹងការរៀបចំស្តង់ដារប្រព័ន្ធគណនេយ្យសាធារណៈ និងការធ្វើអធិការកិច្ចហិរញ្ញវត្ថុ ព្រមទាំងលើកកម្ពស់ការអនុវត្តវិធានការរដ្ឋបាល និងវិន័យហិរញ្ញវត្ថុតាមច្បាប់ជាធរមាន;
- បន្តពង្រឹងការអនុវត្តផែនការសកម្មភាពរបស់គោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យសំខាន់ៗរួមមាន៖ ក).កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ខ).យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥, គ).យុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ ២០១៩-២០២៥, ឃ).យុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០១៩- ២០២៣, ង).យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥ និង ច).យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥;
- បន្តជំរុញការអនុវត្តយន្តការចូលរួមធ្វើសហហិរញ្ញប្បទាន (co-financing) និងចែករំលែកហានិភ័យ (risk sharing) ជាមួយវិស័យឯកជន;
- អនុវត្តអនុក្រឹត្យស្ដីពីការគ្រប់គ្រងការវិនិយោគសាធារណៈ ឱ្យមានប្រសិទ្ធភាពខ្ពស់;
- រៀបចំគោលការណ៍ និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងជំរុញប្រសិទ្ធភាពនៃការរៀបចំផែនការនៃការថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ជាពិសេសការគិតគូរ និងឈានទៅផ្សារភ្ជាប់រវាងគម្រោងស្ថាបនា និងជួសជុល និងគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធឱ្យបានទាន់ពេលវេលា;
- បន្តអនុវត្តក្របខ័ណ្ឌគោលនយោបាយស្ដីពីការគ្រប់គ្រងបំណុលសាធារណៈរបស់រាជរដ្ឋាភិបាល ដោយបន្តគោរពតាមគោលការណ៍គន្លឹះ ទាំងទំហំ និងកម្រិតពិដាន ដើម្បីចូលរួមជំរុញការតភ្ជាប់, និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែង ក្នុងវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល។ លើសពីនេះ បន្តពង្រឹង

ប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ទាំងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ, ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន តាមរយៈ៖ ១). ការអនុវត្តប្រកាសស្ដីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពីនីតិវិធី និងបែបបទអនុវត្តចំណាយវិនិយោគសាធារណៈ ហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ ឱ្យកាន់តែមានភាពច្បាស់លាស់គ្រប់ដំណាក់កាល, ២).ការធ្វើបច្ចុប្បន្នកម្មនីតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ និង ៣).ការរៀបចំបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

## ២.៣-ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២១-២០២៣

ក្របខ័ណ្ឌថវិការយៈពេលមធ្យម (ក.ថ.ម) ត្រូវបានដាក់អនុវត្តសាកល្បងចាប់ពីឆ្នាំ ២០២០ ដោយចាប់ផ្ដើមពីការកំណត់**ពិតានចំណាយគោលផ្នែកចំណាយចរន្ត**សម្រាប់គ្រប់ក្រសួង ស្ថាប័ន ហើយការកំណត់**ពិតានចំណាយគោលផ្នែកចំណាយមូលធន**សម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ ត្រូវបានចាប់ផ្ដើមអនុវត្តផងដែរនៅក្នុងឆ្នាំ ២០២១ សម្រាប់ក្រសួង-ស្ថាប័នចំនួន ០៧ ដែលទទួលបានកញ្ចប់ចំណាយមូលធនជាទៀងទាត់ រួមមាន ៖ ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងមហាផ្ទៃ, និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ការកំណត់ពិតានចំណាយគោលដល់កម្រិតក្រសួង-ស្ថាប័ន ធ្វើឡើងដើម្បីពង្រឹងគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា(ផ.យ.ថ),ការបន្តពង្រឹងវិន័យថវិកា, ការបង្កើនប្រសិទ្ធភាពចំណាយ និងការកែលម្អការវិភាជធនធានសាធារណៈជារួម។

នៅក្នុងការអនុវត្តនេះ, *ការកំណត់ពិតានចំណាយគោល (Baseline Ceiling)* ត្រូវបានជ្រើសរើសជាអភិក្រមនៃការអនុវត្ត ដើម្បីផ្ដល់មូលដ្ឋានច្បាស់លាស់មួយក្នុងផ្ដល់កញ្ចប់ថវិកា។ ពិតានចំណាយគោល "គឺជាកញ្ចប់ថវិកាដែលក្រសួង-ស្ថាប័នអាចនឹងទទួលបានសម្រាប់ប្រតិបត្តិការសកម្មភាពការងារ និងកម្មវិធីដែលមានលក្ខណៈជាប្រចាំ ដោយគិតគូរបញ្ចូលនូវកត្តាតម្រូវការ (demand driver) ប៉ុន្តែ ត្រូវបានកាត់ចេញនូវទំហំចំណាយនៃគោលនយោបាយ និង/ឬ សកម្មភាពមិនប្រចាំ **និង/ឬ លទ្ធភាពដែល**ត្រូវបានវាយតម្លៃថាមិនមានប្រសិទ្ធភាព, ដោយឡែក ចំពោះចំណាយសម្រាប់ការកែលម្អផលិតភាពការងារ, ការលើកកម្ពស់ប្រសិទ្ធភាព និងការអនុវត្តគោលនយោបាយថ្មី នឹងផ្ដល់ជូនបន្ថែមទៀតតាមលទ្ធភាពថវិកាជាក់ស្ដែងក្នុងឆ្នាំនីមួយៗ ហើយកញ្ចប់ថវិកាទាំងនេះនឹងត្រូវសម្រេចតាមរយៈការពិភាក្សាចរចាថវិកាប្រចាំឆ្នាំ។ អភិក្រមនេះនឹងត្រូវកែលម្អជាបណ្ដើរៗរហូតដល់ឆ្នាំ ២០២៥ ដើម្បីប្រែក្លាយ **ក.ថ.ម** ឱ្យក្លាយជាក្របខ័ណ្ឌដែលធានាបាននូវធនធានហិរញ្ញវត្ថុ និងថវិកាកាន់តែច្បាស់លាស់សម្រាប់រយៈពេលមធ្យម សម្រាប់គាំទ្រដល់ការសម្រេចបានគោលបំណងគោលនយោបាយ។

តាមគោលការណ៍នេះ **រូបមន្តពិតានចំណាយគោលផ្នែកចំណាយចរន្ត**សម្រាប់ផ្ដល់ដល់ក្រសួង-ស្ថាប័ន និងឧបត្ថម្ភធនគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានគិតគូរគណនាដោយផ្អែកជាចម្បងលើថវិកាចំណាយប្រចាំនៃឆ្នាំថវិកា (ឆ្នាំ N) ដោយបូកបន្ថែមថវិកាសម្រាប់អនុវត្តគោលនយោបាយថ្មីដែលអនុម័តនៅឆ្នាំថវិកា (ឆ្នាំ N) និងត្រូវចាត់ទុកជាចំណាយប្រចាំសម្រាប់ឆ្នាំគ្រោងថវិកា (ឆ្នាំ N+1) ប៉ុន្តែត្រូវកាត់ចេញវិញនូវចំណាយមិនប្រចាំ។ បន្ទាប់ពីនេះ ថវិកាចំណាយប្រចាំនៃឆ្នាំថវិកា (ឆ្នាំ N) ត្រូវកាត់ចេញនូវថវិកាសម្រាប់អនុវត្តគោលនយោបាយដែល

អនុម័តនៅឆ្នាំមុន (ឆ្នាំ N-1) ដែលមិនបានអនុវត្ត។ ដោយឡែក សមាសធាតុផ្សេងៗទៀត ដូចជា អត្រាប្រែប្រួលនៃប្រាក់បៀវត្ស កត្តាអតិផរណា និងកត្តាតម្រូវការ នឹងត្រូវសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្អែកលើការប្រជុំពិភាក្សាជាមួយនឹងក្រសួង-ស្ថាប័ននីមួយៗ។ សរុបមក **ពិតានចំណាយគោល**ឆ្នាំ ២០២១-២០២៣ ផ្តល់នូវការធានាធនធានហិរញ្ញវត្ថុ និងថវិកាជូនដល់គ្រប់ក្រសួង-ស្ថាប័ន *ដូចដែលបានរៀបចំ និងមានភ្ជាប់ជូនក្នុងតារាង ១ និងឧបសម្ព័ន្ធ ១* សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣។

## ៣-រចនាសម្ព័ន្ធ និងគោលការណ៍នៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ បានកំណត់គោលដៅរួមនៃការប្រមូលចំណូល ដោយបានដាក់ចេញនូវវិធានការចាំបាច់ និងជាក់ស្តែងដែលត្រូវអនុវត្តក្នុងឆ្នាំ ដើម្បីសម្រេចគោលដៅទាំងនេះ និងបានកំណត់គោលដៅរួមនៃការអនុវត្តចំណាយ និងដាក់ចេញអាទិភាពគោល-នយោបាយសំខាន់ៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ដូច្នេះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចបានកំណត់ខាងលើ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន ឱ្យបានល្អត្រឹមត្រូវតាមទិសដៅនេះ និងជាក់ស្តែង។ ទន្ទឹមនេះ ដើម្បីជាមូលដ្ឋានសម្រាប់ក្រសួង-ស្ថាប័ន អាចរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈឯកភាពគ្នាទាំងរចនាសម្ព័ន្ធ និងទាំងខ្លឹមសារ ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវបានរៀបចំតាមទម្រង់ដូចខាងក្រោម៖

- ផ្នែកទី១: **អំពីសេចក្តីផ្តើម**

ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ របស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវបានរៀបចំឡើងដោយចាប់ផ្តើមគូសរំលេចអំពីតួនាទី និងបេសកកម្មរបស់ក្រសួង-ស្ថាប័ន, អំពីស្ថានភាពជាក់ស្តែងនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៩-២០២១ និងការប៉ាន់ស្មានស្ថានភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២ ធៀបនឹងគោលដៅសូចនាករដែលបានកំណត់ និងលើកឡើងបញ្ហាប្រឈមដែលត្រូវដោះស្រាយក្នុងឆ្នាំ ២០២០ និងឆ្នាំខាងមុខ។ បន្ទាប់មកត្រូវបរិយាយរំលេចផងដែរ អំពីវិធានការគោលនយោបាយសំខាន់ៗ ដែលក្រសួង-ស្ថាប័នបានដាក់ចេញ រួមទាំងគោលនយោបាយតាមវិស័យ និងអន្តរវិស័យ។ **សូមរៀបចំខ្លឹមសារនៃផ្នែកទី ១ នេះ ទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

- ផ្នែកទី២: **អំពីគោលបំណងគោលនយោបាយ**

គោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ត្រូវបានរៀបចំ*ដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤* និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣។ ទោះបីជារួម គោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ មិនមែនជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ ប៉ុន្តែក្រសួង-ស្ថាប័នខ្លះ គួរពិនិត្យឡើងវិញនូវគោលបំណងគោលនយោបាយ ដោយផ្សារភ្ជាប់ទៅនឹងអាទិភាពគោល-នយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី ៦ នៃរដ្ឋសភា ដើម្បីធានាថាគោលនយោបាយដែលបានកំណត់មានភាពត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ និងឆ្លើយតបបានកាន់តែច្បាស់លាស់ ទៅនឹងគោលនយោបាយតាមវិស័យរបស់ខ្លួន និង

គោលដៅរួមរបស់រាជរដ្ឋាភិបាល។ ជាគោលការណ៍ *ក្រសួង-ស្ថាប័ននីមួយៗត្រូវមានគោលបំណងគោលនយោបាយមិនលើសពី ២ ឡើយ*។ សូមរៀបចំខ្លឹមសារនៃផ្នែកទី ២ នេះទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។

- ផ្នែកទី៣: **អំពីកម្មវិធី**

*ការរៀបចំកម្មវិធី ត្រូវឆ្លើយតបនឹងគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងត្រូវពណ៌នាអំពីគោលបំណងនៃកម្មវិធីនីមួយៗឱ្យបានច្បាស់លាស់ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ពីការផ្សារភ្ជាប់រវាងកម្មវិធីទៅនឹងគោលនយោបាយ*។ ដូច្នេះ នៅក្នុងផ្នែកនេះ *គ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពថវិកាត្រូវពិនិត្យឡើងវិញនូវឈ្មោះកម្មវិធី និងកែសម្រួលឱ្យកាន់តែល្អប្រសើរនូវឈ្មោះកម្មវិធីទាំងនោះ ដើម្បីពង្រឹងគុណភាពរចនាសម្ព័ន្ធកម្មវិធីក្នុងគោលបំណងពង្រឹងបន្ថែមទៀតនូវការផ្សារភ្ជាប់ថវិកា ទៅនឹងគោលបំណងគោលនយោបាយក្នុងដំណើរឈានទៅអនុវត្តថវិកាសមិទ្ធកម្មដែលនឹងចាប់អនុវត្តពីឆ្នាំ ២០២២*។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគិតគូរដល់ការចូលរួមអនុវត្តការងារដែលមានចរិតជាអន្តរវិស័យ ដូចជា គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម បញ្ញាយេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ពីគ្រោះមហន្តរាយជាដើមផងដែរ។ ចំពោះការគាំទ្រផ្នែកបច្ចេកទេសលើរបៀបរៀបចំគម្រោងថវិកាដែលទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ក្រសួង-ស្ថាប័នពាក់ព័ន្ធអាចធ្វើទំនាក់ទំនងផ្ទាល់ជាមួយនឹងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនៃក្រសួងបរិស្ថានពាក់ព័ន្ធនឹងកិច្ចការនេះ។ ជាគោលការណ៍ ***ក្រសួង-ស្ថាប័ននីមួយៗ អាចមានកម្មវិធីមិនឱ្យលើសពីចំនួន ៥ ឡើយ*** ប៉ុន្តែចំពោះអនុកម្មវិធី អាចមានចំនួនសមស្របទៅតាមការចាំបាច់ ដែលបម្រើឱ្យគោលបំណងរួមនៃកម្មវិធីនីមួយៗ។

កម្មវិធី គឺជាឧបករណ៍ដែលបង្កើតឡើង ដើម្បីឱ្យអគ្គនាយកដ្ឋាន/នាយកដ្ឋាន ក្រោមឱវាទរបស់ក្រសួង-ស្ថាប័ន ដាក់ចេញនូវ**អនុកម្មវិធី** និង**ចង្កោមសកម្មភាព** សម្រាប់ជាមូលដ្ឋាននៃការលើកគម្រោងថវិកាដើម្បីអនុវត្តកម្មវិធីទាំងនោះ ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងផ្នែកទី ២។ គួរកត់សម្គាល់ថា ចង្កោមសកម្មភាពសំដៅលើសកម្មភាពចម្បងៗ ដែលអាចមានចំនួនសមស្របទៅតាមការចាំបាច់សម្រាប់បម្រើឱ្យគោលបំណងរួមនៃអនុកម្មវិធីនីមួយៗ ហើយចង្កោមសកម្មភាពមួយ អាចមានសកម្មភាពតូចៗមួយចំនួនដែលរួមចំណែកបង្កើតធាតុចេញ (Output) សម្រាប់ចង្កោមសកម្មភាពនោះ។

កម្មវិធី ត្រូវមានខ្លឹមសារទូលាយ និងមានលក្ខណៈគ្របដណ្តប់បានទាំងស្រុង គ្រប់តួនាទីភារកិច្ច និងបេសកកម្មរបស់ក្រសួង-ស្ថាប័ននីមួយៗ ព្រមទាំងមានលក្ខណៈសមាហរណកម្មក្នុងកម្រិតវិស័យ ដោយត្រូវគ្របដណ្តប់លើគម្រោង ឬសកម្មភាពការងារទាំងអស់ ទាំងគម្រោង ឬសកម្មភាពការងារដែលហិរញ្ញប្បទានដោយថវិការដ្ឋ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ទាំងថវិកាចរន្ត និងថវិកាមូលធន។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័នត្រូវកំណត់អង្គភាពទទួលខុសត្រូវ ដែលហៅថា **អង្គភាពថវិកា** និងអ្នកគ្រប់គ្រងទៅតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធី (កម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព)។ ***នៅក្នុងឆ្នាំ ២០២១ ក្រសួង-ស្ថាប័នត្រូវបង្កើនចំនួនអង្គភាពថវិកាឱ្យបានជាអតិបរមាដល់អង្គភាពទទួលខុសត្រូវកម្មវិធី និង/ឬ អនុកម្មវិធី***។

ទន្ទឹមនេះ ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ប្រព័ន្ធថវិកា ក្រសួង-ស្ថាប័ននីមួយៗ ត្រូវកំណត់ភារកិច្ច វិសាលភាពការងារ និងក្របខ័ណ្ឌទទួលខុសត្រូវរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ឱ្យច្បាស់លាស់នៅក្នុងរចនាសម្ព័ន្ធកម្មវិធី។ មន្ទីរជំនាញរាជធានី-ខេត្ត មិនចាំបាច់ត្រូវមានកម្មវិធីដោយឡែកទេ ព្រោះមន្ទីរជំនាញ

រាជធានី-ខេត្ត គឺជាដៃ ឬខ្សែបណ្ដោយរបស់ក្រសួងនៅតាមរាជធានី-ខេត្ត ដែលមានភារកិច្ចចូលរួមចំណែកអនុវត្ត បណ្ដាកម្មវិធីរបស់ក្រសួង-ស្ថាប័ន។

ក្នុងន័យនេះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវណែនាំមន្ទីរជំនាញនៅរាជធានី-ខេត្តរៀងខ្លួន អំពីអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីនីមួយៗ ដោយផ្អែកលើមុខងារ វិសាលភាពការងារ និងលក្ខណៈដោយឡែកនៃគោលនយោបាយ និងសេវាសាធារណៈរបស់ក្រសួង-ស្ថាប័នរៀងខ្លួន ដើម្បីឱ្យមន្ទីរជំនាញរាជធានី-ខេត្តរបស់ខ្លួនដឹងច្បាស់អំពីទីតាំងនៃអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីនីមួយៗរបស់ក្រសួង-ស្ថាប័នរៀងខ្លួន។ ជាទូទៅ មន្ទីរជំនាញមួយអាចមានចង្កោមសកម្មភាពគាំទ្រគ្រប់កម្មវិធីរបស់ក្រសួង-ស្ថាប័ន ឬអាចមានចង្កោមសកម្មភាពគាំទ្រ ២ ទៅ ៣ ដោយផ្អែកតាមមុខងារ និងភារកិច្ចរបស់មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ននីមួយៗ។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) **ត្រូវរៀបចំផ្នែកទី ៣ នេះ ទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

- **ផ្នែកទី៤: សូចនាករ និងគោលដៅសូចនាករ នៃសមិទ្ធកម្ម ឬលទ្ធផល**

គោលបំណងគោលនយោបាយ កម្មវិធី និងអនុកម្មនីមួយៗ ត្រូវមានសូចនាករសម្រាប់វាស់វែងលទ្ធផល ឬសមិទ្ធកម្ម ហើយត្រូវកំណត់គោលដៅសូចនាករលទ្ធផលដែលចង់សម្រេចបានសម្រាប់ជាមូលដ្ឋាននៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្ត។ ក្នុងការកំណត់សូចនាករសម្រាប់ការវាស់វែងក្រសួង-ស្ថាប័ននីមួយៗ ត្រូវកំណត់ទាំងសូចនាករលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ។

សូចនាករលទ្ធផលក្នុងឆ្នាំ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់លទ្ធផល/សមិទ្ធកម្មនៃការអនុវត្តអនុកម្មវិធី ចង្កោមសកម្មភាព ទៅតាមគោលដៅដែលបានកំណត់ក្នុងរយៈពេលជាក់លាក់មួយដែលមិនលើសពីមួយឆ្នាំ។ រីឯសូចនាករលទ្ធផលចុងក្រោយ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់លទ្ធផល/សមិទ្ធកម្មចុងក្រោយនៃកម្មវិធី។

ក្រសួង-ស្ថាប័ននីមួយៗ អាចកែលម្អសូចនាករតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធីនីមួយៗ តាមរយៈការបន្ថែមសូចនាករថ្មី និងកែសម្រួលសូចនាករចាស់ដែលបានកំណត់កន្លងមក។ ការជ្រើសរើសសូចនាករនីមួយៗ ត្រូវមានការពន្យល់ពីមូលហេតុឱ្យច្បាស់លាស់។ ចំពោះសូចនាករចាស់ត្រូវបញ្ជាក់អំពីស្ថានភាពនៃការអនុវត្តឆ្នាំ ២០១៩ ការព្យាករណ៍ស្ថានភាពនៃការអនុវត្តក្នុងឆ្នាំ ២០២០ និងធ្វើបច្ចុប្បន្នភាពតាមការជាក់ស្តែង។

**កម្មវិធីនីមួយៗ អាចមានសូចនាករលទ្ធផលចុងក្រោយយ៉ាងច្រើនចំនួន ៣ និងសូចនាករលទ្ធផលក្នុងឆ្នាំមួយចំនួន** ដើម្បីធានានូវការសម្រេចបានលទ្ធផលជាក់លាក់នៃការអនុវត្តកម្មវិធី។ ជារួម បន្ទាប់ពីការជ្រើសរើស និងកំណត់បាននូវសូចនាករសមស្របរួចហើយ ចាំបាច់ត្រូវកំណត់គោលដៅនៃសូចនាករ ទាំងគោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ និងគោលដៅសូចនាករលទ្ធផលចុងក្រោយ។ គោលដៅសូចនាករទាំងពីរប្រភេទនេះចាំបាច់ត្រូវឱ្យមានទំនាក់ទំនងគ្នា និងឆ្លើយតបគ្នាយ៉ាងមានប្រសិទ្ធភាព ដើម្បីធានានូវការសម្រេចបានលទ្ធផលនៃគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងរយៈពេលជាក់លាក់មួយ។ គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំមានលក្ខណៈជាបរិមាណ ឬ/និងជាគុណភាពប្រចាំឆ្នាំ ដែលជាសមិទ្ធកម្មនៃការអនុវត្តកម្មវិធីនីមួយៗ។ រីឯគោលដៅសូចនាករលទ្ធផលចុងក្រោយ គឺជាគោលដៅសមិទ្ធកម្មចុងក្រោយជាបរិមាណ ឬ/និងជាគុណភាព ដែលជា

លទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធី នៅក្នុងរយៈពេលមធ្យម និងវែង (លើសពី ១ ឆ្នាំ)។ ក្នុងការកំណត់គោលដៅសូចនាករ កត្តាចាំបាច់និងសំខាន់បំផុត គឺត្រូវដឹងអំពីស្ថានភាពបច្ចុប្បន្នរបស់សូចនាករទាំងនោះ ទើបអាចទៅកំណត់គោលដៅដែលចង់បាន ដើម្បីឱ្យឆ្លើយតបបានទៅនឹងគោលបំណងគោលនយោបាយដែលបានកំណត់ ហើយការកំណត់គោលដៅនេះ ចាំបាច់ត្រូវតែមានភាពសមស្រប និងប្រាកដនិយមដែលអាចអនុវត្តបាន។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ( សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) **ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៤ នេះ ទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ**។ *ក្នុងដំណើរឈានទៅអនុវត្តថវិកាសមិទ្ធកម្មនៅឆ្នាំ ២០២២ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងផ្ដោតការយកចិត្តទុកដាក់ជាបណ្ដើរៗលើសមិទ្ធកម្ម ដែលតម្រូវឱ្យក្រសួង-ស្ថាប័នយកចិត្តទុកដាក់កែលម្អសូចនាករឱ្យបានល្អប្រសើរ និងមានមូលដ្ឋានទិន្នន័យច្បាស់លាស់។*

- ផ្នែកទី៥: **ការកំណត់ធនធានថវិកា**

ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគ្រោងទាំងធនធានថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់អនុវត្តកម្មវិធី សម្រាប់រយៈពេលបីឆ្នាំរំកិល (២០២១-២០២៣)។

### ក-ការគ្រោងចំណូល

ការគ្រោងចំណូល គឺជាការគ្រោងសម្រាប់រយៈពេល ៣ ឆ្នាំ ២០២១-២០២៣ ដោយរួមទាំងចំណូលថវិការដ្ឋដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួង-ស្ថាប័ន និងចំណូលដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងប្រភពផ្សេងៗទៀត។ នៅក្នុងការគ្រោងចំណូលក្រសួង-ស្ថាប័នរួមទាំង មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវផ្ដោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម៖

- គោលដៅសូចនាករចំណូលនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបានដាក់ចេញនៅក្នុងសារាចរណែនាំនេះ
- ការវាយតម្លៃការអនុវត្តការប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត
- ការដាក់ចេញវិធានការដាក់ស្ដែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ ដើម្បីបង្កើនការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំផ្នែកនេះទៅតាម **តារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ**។ នៅក្នុងផ្នែកនេះ ចំពោះក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដែលមិនមានប្រភពចំណូល គឺពុំតម្រូវឱ្យរៀបចំឡើយ។

ទន្ទឹមនេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានប្រភពចំណូល គឺត្រូវរៀបចំដាក់ចេញវិធានការដាក់ស្ដែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ សម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ *ផ្ទុយទៅវិញ ការគ្រោងចំណូលមិនអស់*

*សក្តានុពលដែលមាន គឺជាកម្មវត្ថុនៃការរឹតត្បិតចំណាយនៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់ក្រសួង-ស្ថាប័ន ដែលមានការកិច្ចប្រមូលចំណូល។*

**ខ-ការគ្រោងចំណាយថវិកា**

ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល ៣ ឆ្នាំ ២០២១-២០២៣ ទៅតាមកម្មវិធីនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន រួមទាំងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៥ នេះ **តាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ**។

ក្នុងការគណនាអំពីតម្រូវការថវិកា ដើម្បីអនុវត្តកម្មវិធីនីមួយៗ ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម៖

ទី១-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយហិរញ្ញវត្ថុសាធារណៈដែលរាជរដ្ឋាភិបាលបានដាក់ចេញ តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមានគោលដៅសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដូចជា កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងគោលដៅសូចនាករចំណាយ ព្រមជាមួយនឹងគោលនយោបាយអាទិភាពចំណាយទាំងផ្នែកចំណាយចរន្ត និងចំណាយមូលធន (ឬហៅថា ចំណាយវិនិយោគ)។ *ដូចគ្នានេះដែរ ពិតានចំណាយគោលនៃចំណាយចរន្តរបស់ក្រសួង-ស្ថាប័ន ត្រូវបានផ្តល់ជាកញ្ចប់ថវិកាសម្រាប់រយៈពេល ៣ ឆ្នាំ (២០២១-២០២៣) ទាំងផ្នែកចំណាយបន្ទុកបុគ្គលិក (ដោយមិនគិតបញ្ចូលនូវរង្វាន់ពីសេវាសាធារណៈ) និងចំណាយមិនមែនបន្ទុកបុគ្គលិកទៅតាមគោលការណ៍ដែលលម្អិតនៅក្នុងផ្នែក ២.៣*។

ទី២-ការវាយតម្លៃអំពីសមត្ថភាពក្នុងការអនុវត្តចំណាយក្នុងរយៈពេលកន្លងមក និងការប៉ាន់ស្មានសមត្ថភាពអនុវត្តចំណាយក្នុងឆ្នាំ ២០២០ ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ បាននិងកំពុងអនុវត្ត,

ទី៣-ការកំណត់តម្រូវការថវិកាតាមឆ្នាំនីមួយៗ ត្រូវគណនាចំណាយប្រកបដោយសុក្រឹតភាពទៅតាមតម្រូវការជាក់ស្តែងនៃកម្មវិធីនីមួយៗ ដោយត្រូវគិតគូរឈរលើទិដ្ឋភាពបី៖

- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានស្រាប់ដែលត្រូវបន្តអនុវត្ត ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងខ្លួន,
- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានលក្ខណៈបញ្ចប់ត្រឹមមួយឆ្នាំ , និង
- ផែនការសកម្មភាព ឬសកម្មភាពការងារថ្មី ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងខ្លួន។

ដូច្នេះ ផ្អែកលើគោលការណ៍ទាំងបីខាងលើនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទទាំងអស់ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោងតម្រូវការចំណាយសម្រាប់ឆ្នាំ ២០២១-២០២៣ តាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា ដូចខាងក្រោម៖

• **ចំណាយបន្ទុកបុគ្គលិក** (ជំពូក ៦៤)៖ សម្រាប់ឆ្នាំ ២០២១, ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចជាតិនៅបន្តរងផលប៉ះពាល់អវិជ្ជមានពីជំងឺកូវីដ-១៩, ត្រូវគ្រោងតាមគោលការណ៍៖ (១)-តាមមូលដ្ឋាននៃចំនួនក្របខ័ណ្ឌមន្ត្រីរាជការឆ្នាំ២០២០ ហើយចំនួនក្របខ័ណ្ឌថ្មីត្រូវគ្រោងជ្រើសរើសយ៉ាងច្រើនស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍, (២)-**សន្ទស្សន៍បៀវត្សមូលដ្ឋាន និងកម្រិតប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការទាំងអស់ រួមទាំងប្រាក់ឧបត្ថម្ភមន្ត្រីជាប់កិច្ចសន្យា និងប្រាក់សោធន ត្រូវរក្សាស្មើនឹងកម្រិតឆ្នាំ ២០២០។** ដោយឡែកសម្រាប់ឆ្នាំ ២០២២ និងឆ្នាំ ២០២៣ ត្រូវគ្រោងដោយផ្អែកលើមូលដ្ឋាននៃចំនួនក្របខ័ណ្ឌ និងកម្រិតបៀវត្សនៃឆ្នាំ ២០២១ និងឆ្នាំ ២០២២ រៀងគ្នា ហើយចំនួនក្របខ័ណ្ឌថ្មីត្រូវគ្រោងជ្រើសរើសយ៉ាងច្រើន ស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍, (៣)-**ផ្អាកការផ្តល់ប្រាក់ឧបត្ថម្ភជូនមន្ត្រីរាជការសម្រាប់ពិធីបុណ្យចូលឆ្នាំខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌ** (៥ ម៉ឺនរៀល ក្នុង ១ នាក់) សម្រាប់ឆ្នាំ ២០២១ ។

• **ចំណាយក្រៅបន្ទុកបុគ្គលិក** (ជំពូក ៦០ ការទិញ, ជំពូក ៦១ សេវាកម្ម, ជំពូក ៦២ អត្ថប្រយោជន៍សង្គម, ជំពូក ៦៥ ឧបត្ថម្ភធន) ជាសរុបសម្រាប់ឆ្នាំ ២០២១ ត្រូវគ្រោងតាមគោលការណ៍ ដូចខាងក្រោម៖

- **ក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាល៖** ត្រូវគ្រោងថវិកាទៅតាមទំហំពិតានចំណាយគោលឆ្នាំ ២០២១-២០២៣។ សម្រាប់ឆ្នាំ ២០២១ ពិតានចំណាយគោលត្រូវបានផ្តល់ជូនក្នុងកម្រិតនៃទំហំចំណាយដែលបានធ្វើវិចារណកម្មរួចនៅក្នុងឆ្នាំ ២០២០ ព្រមជាមួយនឹងការកាត់ចេញនូវមុខសញ្ញាចំណាយមិនប្រចាំ, សកម្មភាពដែលចប់ ឬសកម្មភាពដែលមិនអនុវត្ត។ ជាមួយគ្នានេះដែរ កញ្ចប់ពិតានចំណាយគោលនេះនឹងមិនទទួលបានជាស្វ័យប្រវត្តិនោះទេ គឺនៅជាកម្មវត្ថុនៃការពិនិត្យ និងពិភាក្សាដើម្បីបង្កើនប្រសិទ្ធភាពក្នុងការវិភាជន៍ថវិកា និងប្រតិបត្តិការចំណាយ។
- **មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)៖ ផ្អែកលើទំហំពិតានចំណាយគោលរួមដែលផ្តល់ជូនដល់មន្ទីរជំនាញរាជធានី-ខេត្ត, សម្រាប់ឆ្នាំ ២០២១ មន្ទីរជំនាញរាជធានី-ខេត្តនីមួយៗ និងរដ្ឋបាលរាជធានី-ខេត្ត ត្រូវគ្រោងយ៉ាងច្រើនបំផុត ស្មើនឹងកម្រិតថវិកាអតិបរមានៃទំហំថវិកាឆ្នាំ ២០២០ ដែលបានធ្វើវិចារណកម្មចំណាយរួច (ស្របតាមសារាចរណែនាំអំពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយលើកទី ២ សម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០)។ សម្រាប់ឆ្នាំ ២០២២ និងឆ្នាំ ២០២៣ ត្រូវគ្រោងកើនឡើងក្នុងរង្វង់នៃ**ទំហំពិតានចំណាយគោលរួមដែលមានកំណើនរួមក្នុងរង្វង់ ៣% ធៀបនឹងទំហំពិតានចំណាយគោលរួមឆ្នាំ ២០២១។ ប៉ុន្តែត្រូវកត់សម្គាល់ថា កញ្ចប់ថវិកាដែលគ្រោងផ្តល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យមន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលរាជធានី-ខេត្តនីមួយៗ ដែលទទួលបាននូវការប្រគល់មុខងារពីក្រសួងសុខាភិបាល** ត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- ដោយឡែក សម្រាប់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យអប់រំ ការគ្រោងកញ្ចប់ថវិកាត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុងស្រុកទាំង ១៤ ក្នុងខេត្តបាត់ដំបង សម្រាប់អនុវត្តមុខងារគ្រប់គ្រង ការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។
- **គ្រឹះស្ថានសាធារណៈរដ្ឋបាលនៃក្រសួង-ស្ថាប័ននីមួយៗ** ត្រូវបានផ្តល់កញ្ចប់ថវិកាឧបត្ថម្ភធន សម្រាប់រយៈពេល ៣ ឆ្នាំ (២០២១-២០២៣) **ប៉ុន្តែ ត្រូវកត់សម្គាល់ថា កញ្ចប់ឧបត្ថម្ភធនដែលគ្រោងផ្តល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ** គឺតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ត្រូវផ្តល់ការពន្យល់ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់នូវស្ថានភាពចំណូលផ្ទៃក្នុងរបស់គ្រឹះស្ថាន និងម្យ៉ាងទៀត ក៏ត្រូវកាត់ចេញនូវទំហំចំណាយសម្រាប់សកម្មភាពដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃ ក៏ដូចជាសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់។

- **ចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាជាតិ** (ជំពូក២១)៖ ត្រូវបានផ្តល់ជាពិតានចំណាយគោលសម្រាប់ក្រសួង-ស្ថាប័នចំនួន ០៧ ដែលទទួលបានចំណាយវិនិយោគជាទៀងទាត់ រួមមាន ៖ ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងមហាផ្ទៃ, និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់ និងធារាសាស្ត្រ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងធនធានទឹកនិងឧតុនិយម, និងក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវរៀបចំផែនការវិនិយោគសាធារណៈ ០៣ ឆ្នាំរំកិល ជាបញ្ជីគម្រោងសម្រាប់ឆ្នាំ ២០២១-២០២៣ ហើយផ្អែកតាមផែនការវិនិយោគសាធារណៈនេះ ត្រូវធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគ ជាមួយនឹងគម្រោងចំណាយចរន្ត នៅកម្រិតកម្មវិធី និង អនុកម្មវិធី ដោយភ្ជាប់ជាមួយនូវបញ្ជីគម្រោងដែលបានរៀបចំ។ ចំពោះ ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងមហាផ្ទៃ, និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានចាប់ផ្តើមដាក់ឱ្យអនុវត្តសាកល្បងការរៀបចំផែនការវិនិយោគសាធារណៈ ០៣ ឆ្នាំរំកិលផងដែរ។ ក្រសួងទាំង ០៧ ខាងលើនេះ នឹងមិនទទួលបានកញ្ចប់ពិតានចំណាយគោលជាស្វ័យប្រវត្តិទេ, ការធ្វើអាទិភាវូនីយកម្មគម្រោង និងផ្តល់ថវិកា គឺជាកម្មវត្ថុនៃការពិនិត្យពិភាក្សាតាមយន្តការគណៈកម្មការ ឬ ក្រុមការងារអន្តរក្រសួង។ សម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលមានតម្រូវការចំណាយវិនិយោគ ត្រូវសិក្សាឲ្យបានច្បាស់លាស់ និងរៀបចំលើកសំណើគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំធ្វើអាទិភាវូបនីយកម្មគម្រោង ហើយគោរពស្នើសុំការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច តាមលទ្ធភាពថវិកា និងវិធានការផ្អែកចំណាយដែលបានកំណត់នៅផ្នែកខាងលើនៃសារាចរនេះ។

- **ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍន៍៖** ក្រសួង-ស្ថាប័នដែលបាននិងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការ ឬគ្រោងនឹងទទួលបានហិរញ្ញប្បទាន ស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល(២០២១-២០២៣) ត្រូវគ្រោងឱ្យបានត្រឹមត្រូវ ទៅតាមកិច្ចព្រមព្រៀង ឬអនុស្សារណៈនៃការយោគយល់គ្នា ឬការសន្យាតាមរយៈយន្តការផ្សេងៗ។

- ផ្នែកទី៦: **សេចក្តីសន្និដ្ឋាន**

ផ្នែកចុងក្រោយ គឺជាការសន្និដ្ឋានទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ និងការលើកទិសដៅ និងវិធានការ ដើម្បីសម្រេចគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣។

## ៤-សេចក្តីសន្និដ្ឋាន

ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺជាវិធានការសំខាន់សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំថវិកា និងការបែងចែកធនធានថវិកា។ ក្នុងន័យនេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវត្រួតពិនិត្យឡើងវិញ និងវាយតម្លៃការអនុវត្តកន្លងមក ហើយរៀបចំកែសម្រួលទៅតាមការណែនាំនៃសារាចរនេះ។ ជារួម *គុណភាពនៃផែនការយុទ្ធសាស្ត្រ គឺជាកម្មវត្ថុនៃការរឹតត្បិត ឬលើកទឹកចិត្តចំណាយនៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់គ្រប់ក្រសួង-ស្ថាប័ន។*

សម្រាប់ឆ្នាំ ២០២១ និងបណ្តាឆ្នាំខាងមុខ, ក្រសួង-ស្ថាប័នត្រូវយកចិត្តទុកដាក់កែលម្អផែនការយុទ្ធសាស្ត្រថវិកាឱ្យស្របទៅតាមអាទិភាពគោលនយោបាយ ដែលមាននៅក្នុង *យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤* ដែលជារបៀបវារៈគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមរបស់រាជរដ្ឋាភិបាលអាណត្តិទី ៦ នៃរដ្ឋសភា និងត្រូវគ្រោងចំណាយស្របទៅតាមពិតានគោលរយៈពេល ៣ ឆ្នាំ និងធនធានដទៃទៀតដែលរំពឹងថានឹងទទួលបានពីដៃគូអភិវឌ្ឍន៍ ឬប្រភពដ៏ទៃផ្សេងទៀត ប្រកបដោយភាពជាក់ស្តែងនិយម។

*គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០២១-២០២៣ ដែលមានវិសាលភាពគ្របដណ្តប់ទាំងផែនការយុទ្ធសាស្ត្រថវិការបស់មន្ទីរជំនាញរាជធានី-ខេត្ត របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០២០* ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យនិងបូកសរុប និងស្នើសុំការបំភ្លឺបន្ថែមតាមការចាំបាច់ពីក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។ ដើម្បីសម្រួលដល់ដំណើរការពិនិត្យ និងបូកសរុបផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ននីមួយៗ *គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាមួយច្បាប់ទៅក្រសួង-ស្ថាប័នសាមី និងមួយច្បាប់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) តាមពេលវេលាដែលបានកំណត់ខាងលើ។* ប្រសិនបើក្រសួង-ស្ថាប័នមិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកាតាមពេលវេលាកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យស្នើការវិភាជកញ្ចប់ថវិកាប្រចាំឆ្នាំដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកាឆ្នាំចាស់ និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ រួមទាំងវិធានការវិចារណកម្មចំណាយដែលបានដាក់ចេញនៅក្នុងឆ្នាំ ២០២០។

ទទួលបានសារាចរណែនាំនេះ ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងឱ្យបានទាន់ឱសានវាទ។ ក្នុងករណីក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធមានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេសរៀបចំ ត្រូវទាក់ទងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ **ឱ្យបានទាន់ពេលវេលាតាមកាលកំណត់ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០២០។**

ថ្ងៃអង្គារ ៤រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

  "ដើម្បីជូនជ្រាប"

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-រាជកិច្ច "ដើម្បីចុះផ្សាយ"

-គ្រប់ក្រសួង-ស្ថាប័ន

-គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល

-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត

-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត

-រដ្ឋបាលក្រុង-ស្រុកទាំង ១៤ នៃខេត្តបាត់ដំបង

  "ដើម្បីមុខការ"

-ឯកសារ-កាលប្បវត្តិ

# គម្រោងថវិកាឆ្នាំ ២០២១-២០២៣

# តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២១ | គម្រោងថវិកាឆ្នាំ ២០២២ | គម្រោងថវិកាឆ្នាំ ២០២៣ |
|---|---|---|---|
| **សរុបរួម** | **15.184.315** | **15.157.345** | **15.761.749** |
| **០១. ព្រះបរមរាជវាំង** | **76.554** | **77.160** | **80.738** |
| សរុបចំណាយចរន្ត | **76.554** | **77.160** | **80.738** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 36.249 | 36.249 | 38.786 |
| មិនមែនបន្ទុកបុគ្គលិក | 40.305 | 40.911 | 41.951 |
| **០២. រដ្ឋសភា** | **161.304** | **162.869** | **172.564** |
| សរុបចំណាយចរន្ត | **161.304** | **162.869** | **172.564** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 100.116 | 100.116 | 107.124 |
| មិនមែនបន្ទុកបុគ្គលិក | 61.188 | 62.753 | 65.440 |
| **០៣. ព្រឹទ្ធសភា** | **74.395** | **75.002** | **79.478** |
| សរុបចំណាយចរន្ត | **74.395** | **75.002** | **79.478** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 49.038 | 49.038 | 52.471 |
| មិនមែនបន្ទុកបុគ្គលិក | 25.357 | 25.964 | 27.007 |
| **០៤. ក្រុមប្រឹក្សាធម្មនុញ្ញ** | **12.919** | **12.984** | **13.838** |
| សរុបចំណាយចរន្ត | **12.919** | **12.984** | **13.838** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 10.599 | 10.599 | 11.341 |
| មិនមែនបន្ទុកបុគ្គលិក | 2.320 | 2.385 | 2.497 |
| **០៥.១. ទីស្តីការគណៈរដ្ឋមន្ត្រី** | **413.457** | **415.555** | **423.477** |
| សរុបចំណាយចរន្ត | **413.457** | **415.555** | **423.477** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 61.725 | 61.725 | 66.046 |
| មិនមែនបន្ទុកបុគ្គលិក | 351.732 | 353.830 | 357.432 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 12.757 | 13.140 | 13.797 |
| **០៥.៣. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល** | **39.714** | **40.071** | **41.831** |
| សរុបចំណាយចរន្ត | **39.714** | **40.071** | **41.831** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 16.395 | 16.395 | 17.543 |
| មិនមែនបន្ទុកបុគ្គលិក | 23.319 | 23.676 | 24.288 |
| **០៥.៤. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** | **8.968** | **9.201** | **9.683** |
| សរុបចំណាយចរន្ត | **8.968** | **9.201** | **9.683** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 1.175 | 1.175 | 1.257 |
| មិនមែនបន្ទុកបុគ្គលិក | 7.793 | 8.026 | 8.426 |

# គម្រោងថវិកាឆ្នាំ ២០២១-២០២៣

## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២១ | គម្រោងថវិកាឆ្នាំ ២០២២ | គម្រោងថវិកាឆ្នាំ ២០២៣ |
|---|---|---|---|
| **០៦. ក្រសួងការពារជាតិ** | **2.513.342** | **2.522.895** | **2.691.440** |
| **សរុបចំណាយចរន្ត** | **2.513.342** | **2.522.895** | **2.691.440** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 2.173.522 | 2.173.522 | 2.325.669 |
| មិនមែនបន្ទុកបុគ្គលិក | 339.820 | 349.373 | 365.771 |
| **០៧.១. ក្រសួងមហាផ្ទៃ-សន្តិសុខសាធារណៈ** | **1.642.665** | **1.652.783** | **1.757.831** |
| **សរុបចំណាយចរន្ត** | **1.627.665** | **1.637.783** | **1.742.831** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 1.252.552 | 1.252.552 | 1.340.231 |
| មិនមែនបន្ទុកបុគ្គលិក | 375.113 | 385.231 | 402.600 |
| **សរុបចំណាយមូលធន** | **15.000** | **15.000** | **15.000** |
| ជំពូក ២១: អចលកម្មរូបី | 15.000 | 15.000 | 15.000 |
| - គម្រោងវិនិយោគ | 15.000 | 15.000 | 15.000 |
| **០៧.២. ក្រសួងមហាផ្ទៃ-រដ្ឋបាលទូទៅ** | **242.399** | **244.767** | **259.192** |
| **សរុបចំណាយចរន្ត** | **237.399** | **239.767** | **254.192** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 147.995 | 147.995 | 158.355 |
| មិនមែនបន្ទុកបុគ្គលិក | 89.404 | 91.772 | 95.838 |
| **សរុបចំណាយមូលធន** | **5.000** | **5.000** | **5.000** |
| ជំពូក ២១: អចលកម្មរូបី | 5.000 | 5.000 | 5.000 |
| - គម្រោងវិនិយោគ | 5.000 | 5.000 | 5.000 |
| **០៨. ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច** | **36.861** | **37.346** | **39.623** |
| **សរុបចំណាយចរន្ត** | **36.861** | **37.346** | **39.623** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 20.636 | 20.636 | 22.081 |
| មិនមែនបន្ទុកបុគ្គលិក | 16.225 | 16.710 | 17.542 |
| **១.ក្រសួង** | **19.942** | **20.164** | **21.419** |
| **សរុបចំណាយចរន្ត** | **19.942** | **20.164** | **21.419** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 12.485 | 12.485 | 13.359 |
| មិនមែនបន្ទុកបុគ្គលិក | 7.457 | 7.679 | 8.061 |
| **៩.មន្ទីរជំនាញ** | **16.920** | **17.182** | **18.203** |
| **សរុបចំណាយចរន្ត** | **16.920** | **17.182** | **18.203** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 8.151 | 8.151 | 8.722 |
| មិនមែនបន្ទុកបុគ្គលិក | 8.769 | 9.031 | 9.482 |

# គម្រោងថវិកាឆ្នាំ ២០២១-២០២៣

## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២១ | គម្រោងថវិកាឆ្នាំ ២០២២ | គម្រោងថវិកាឆ្នាំ ២០២៣ |
|---|---|---|---|
| **០៩. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** | 128.358 | 130.627 | 137.610 |
| សរុបចំណាយចរន្ត | **128.358** | **130.627** | **137.610** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 44.120 | 44.120 | 47.208 |
| មិនមែនបន្ទុកបុគ្គលិក | 84.238 | 86.507 | 90.402 |
| **១០. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | 817.967 | 821.888 | 837.615 |
| សរុបចំណាយចរន្ត | **817.967** | **821.888** | **837.615** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 128.540 | 128.540 | 137.538 |
| មិនមែនបន្ទុកបុគ្គលិក | 689.427 | 693.348 | 700.078 |
| ១.ក្រសួង | **792.232** | **795.743** | **809.924** |
| សរុបចំណាយចរន្ត | **792.232** | **795.743** | **809.924** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 116.476 | 116.476 | 124.629 |
| មិនមែនបន្ទុកបុគ្គលិក | 675.756 | 679.267 | 685.294 |
| ៩.មន្ទីរជំនាញ | **25.735** | **26.145** | **27.692** |
| សរុបចំណាយចរន្ត | **25.735** | **26.145** | **27.692** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 12.064 | 12.064 | 12.908 |
| មិនមែនបន្ទុកបុគ្គលិក | 13.671 | 14.081 | 14.783 |
| **១១. ក្រសួងព័ត៌មាន** | 79.105 | 80.090 | 84.974 |
| សរុបចំណាយចរន្ត | **79.105** | **80.090** | **84.974** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 45.607 | 45.607 | 48.800 |
| មិនមែនបន្ទុកបុគ្គលិក | 33.497 | 34.483 | 36.174 |
| ១.ក្រសួង | **51.971** | **52.631** | **55.816** |
| សរុបចំណាយចរន្ត | **51.971** | **52.631** | **55.816** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 29.299 | 29.299 | 31.350 |
| មិនមែនបន្ទុកបុគ្គលិក | 22.672 | 23.332 | 24.466 |
| ៩.មន្ទីរជំនាញ | **27.134** | **27.459** | **29.157** |
| សរុបចំណាយចរន្ត | **27.134** | **27.459** | **29.157** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 16.308 | 16.308 | 17.450 |
| មិនមែនបន្ទុកបុគ្គលិក | 10.826 | 11.150 | 11.708 |
| **១២. ក្រសួងសុខាភិបាល** | 931.562 | 938.939 | 959.295 |
| សរុបចំណាយចរន្ត | **931.562** | **938.939** | **959.295** |

# គម្រោងថវិកាឆ្នាំ ២០២១-២០២៣

## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២១ | គម្រោងថវិកាឆ្នាំ ២០២២ | គម្រោងថវិកាឆ្នាំ ២០២៣ |
|---|---|---|---|
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 109.860 | 109.860 | 117.550 |
| មិនមែនបន្ទុកបុគ្គលិក | 821.702 | 829.080 | 841.745 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 39.665 | 40.855 | 42.898 |
| **១.ក្រសួង** | **920.114** | **927.316** | **947.061** |
| **សរុបចំណាយចរន្ត** | **920.114** | **927.316** | **947.061** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 105.467 | 105.467 | 112.850 |
| មិនមែនបន្ទុកបុគ្គលិក | 814.647 | 821.848 | 834.211 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 39.665 | 40.855 | 42.898 |
| **៩.សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ** | **11.448** | **11.624** | **12.234** |
| **សរុបចំណាយចរន្ត** | **11.448** | **11.624** | **12.234** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 4.392 | 4.392 | 4.700 |
| មិនមែនបន្ទុកបុគ្គលិក | 7.056 | 7.232 | 7.534 |
| **១៣. ក្រសួងរ៉ែ និងថាមពល** | **40.958** | **41.560** | **44.030** |
| **សរុបចំណាយចរន្ត** | **40.958** | **41.560** | **44.030** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 20.546 | 20.546 | 21.984 |
| មិនមែនបន្ទុកបុគ្គលិក | 20.412 | 21.013 | 22.046 |
| **១.ក្រសួង** | **23.036** | **23.339** | **24.742** |
| **សរុបចំណាយចរន្ត** | **23.036** | **23.339** | **24.742** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 12.608 | 12.608 | 13.490 |
| មិនមែនបន្ទុកបុគ្គលិក | 10.429 | 10.731 | 11.252 |
| **៩.មន្ទីរជំនាញ** | **17.922** | **18.220** | **19.289** |
| **សរុបចំណាយចរន្ត** | **17.922** | **18.220** | **19.289** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 7.938 | 7.938 | 8.494 |
| មិនមែនបន្ទុកបុគ្គលិក | 9.983 | 10.282 | 10.795 |
| **១៤. ក្រសួងផែនការ** | **85.630** | **86.352** | **91.888** |
| **សរុបចំណាយចរន្ត** | **85.630** | **86.352** | **91.888** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 61.395 | 61.395 | 65.693 |
| មិនមែនបន្ទុកបុគ្គលិក | 24.235 | 24.957 | 26.196 |
| **១.ក្រសួង** | **37.533** | **37.959** | **40.313** |
| **សរុបចំណាយចរន្ត** | **37.533** | **37.959** | **40.313** |

# គម្រោងថវិកាឆ្នាំ ២០២១-២០២៣

## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២១ | គម្រោងថវិកាឆ្នាំ ២០២២ | គម្រោងថវិកាឆ្នាំ ២០២៣ |
|---|---|---|---|
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 23.203 | 23.203 | 24.827 |
| មិនមែនបន្ទុកបុគ្គលិក | 14.330 | 14.756 | 15.486 |
| **៩.មន្ទីរជំនាញ** | **48.097** | **48.393** | **51.575** |
| **សរុបចំណាយចរន្ត** | **48.097** | **48.393** | **51.575** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 38.192 | 38.192 | 40.865 |
| មិនមែនបន្ទុកបុគ្គលិក | 9.905 | 10.201 | 10.710 |
| **១៥. ក្រសួងពាណិជ្ជកម្ម** | **96.156** | **97.686** | **103.213** |
| **សរុបចំណាយចរន្ត** | **96.156** | **97.686** | **103.213** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 41.414 | 41.414 | 44.313 |
| មិនមែនបន្ទុកបុគ្គលិក | 54.742 | 56.273 | 58.900 |
| **១.ក្រសួង** | **75.797** | **77.002** | **81.306** |
| **សរុបចំណាយចរន្ត** | **75.797** | **77.002** | **81.306** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 31.933 | 31.933 | 34.168 |
| មិនមែនបន្ទុកបុគ្គលិក | 43.864 | 45.069 | 47.138 |
| **៩.មន្ទីរជំនាញ** | **20.359** | **20.684** | **21.907** |
| **សរុបចំណាយចរន្ត** | **20.359** | **20.684** | **21.907** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 9.481 | 9.481 | 10.145 |
| មិនមែនបន្ទុកបុគ្គលិក | 10.878 | 11.203 | 11.763 |
| **១៦. ក្រសួងអប់រំ យុវជន និងកីឡា** | **3.099.704** | **2.988.159** | **3.048.168** |
| **សរុបចំណាយចរន្ត** | **3.009.704** | **2.898.159** | **2.958.168** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 2.461.241 | 2.338.757 | 2.379.987 |
| មិនមែនបន្ទុកបុគ្គលិក | 548.463 | 559.402 | 578.181 |
| **សរុបចំណាយមូលធន** | **90.000** | **90.000** | **90.000** |
| ជំពូក ២១: អចលកម្មរូបី | 90.000 | 90.000 | 90.000 |
| - គម្រោងវិនិយោគ | 90.000 | 90.000 | 90.000 |
| **១.ក្រសួង** | **411.355** | **415.218** | **428.362** |
| **សរុបចំណាយចរន្ត** | **321.355** | **325.218** | **338.362** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 93.020 | 93.020 | 99.531 |
| មិនមែនបន្ទុកបុគ្គលិក | 228.335 | 232.199 | 238.831 |
| **សរុបចំណាយមូលធន** | **90.000** | **90.000** | **90.000** |

# គម្រោងថវិកាឆ្នាំ ២០២១-២០២៣

# តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២១ | គម្រោងថវិកាឆ្នាំ ២០២២ | គម្រោងថវិកាឆ្នាំ ២០២៣ |
|---|---|---|---|
| ជំពូក ២១: អចលកម្មរូបី | 90.000 | 90.000 | 90.000 |
| - គម្រោងវិនិយោគ | 90.000 | 90.000 | 90.000 |
| **១.១. ផ្នែកអប់រំ** | **325.600** | **328.339** | **339.440** |
| **សរុបចំណាយចរន្ត** | **235.600** | **238.339** | **249.440** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 91.413 | 91.413 | 97.811 |
| មិនមែនបន្ទុកបុគ្គលិក | 144.187 | 146.926 | 151.628 |
| **សរុបចំណាយមូលធន** | **90.000** | **90.000** | **90.000** |
| ជំពូក ២១: អចលកម្មរូបី | 90.000 | 90.000 | 90.000 |
| - គម្រោងវិនិយោគ | 90.000 | 90.000 | 90.000 |
| **១.២. ផ្នែកឧត្តមសិក្សា** | **30.578** | **31.290** | **32.608** |
| **សរុបចំណាយចរន្ត** | **30.578** | **31.290** | **32.608** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 1.380 | 1.380 | 1.476 |
| មិនមែនបន្ទុកបុគ្គលិក | 29.198 | 29.910 | 31.132 |
| **១.៣. ផ្នែកយុវជន និងកីឡា** | **55.177** | **55.590** | **56.314** |
| **សរុបចំណាយចរន្ត** | **55.177** | **55.590** | **56.314** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 227 | 227 | 243 |
| មិនមែនបន្ទុកបុគ្គលិក | 54.950 | 55.363 | 56.071 |
| **៩.មន្ទីរជំនាញ** | **2.688.349** | **2.572.941** | **2.619.806** |
| **សរុបចំណាយចរន្ត** | **2.688.349** | **2.572.941** | **2.619.806** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 2.368.221 | 2.245.738 | 2.280.456 |
| មិនមែនបន្ទុកបុគ្គលិក | 320.127 | 327.203 | 339.350 |
| **១៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **265.464** | **268.513** | **283.268** |
| **សរុបចំណាយចរន្ត** | **249.464** | **252.513** | **267.268** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 136.016 | 136.016 | 145.538 |
| មិនមែនបន្ទុកបុគ្គលិក | 113.448 | 116.496 | 121.730 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 15.378 | 15.839 | 16.631 |
| **សរុបចំណាយមូលធន** | **16.000** | **16.000** | **16.000** |
| ជំពូក ២១: អចលកម្មរូបី | 16.000 | 16.000 | 16.000 |
| - គម្រោងវិនិយោគ | 16.000 | 16.000 | 16.000 |
| **១.ក្រសួង** | **156.132** | **158.173** | **166.405** |

# គម្រោងថវិកាឆ្នាំ ២០២១-២០២៣

## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២១ | គម្រោងថវិកាឆ្នាំ ២០២២ | គម្រោងថវិកាឆ្នាំ ២០២៣ |
|---|---|---|---|
| **សរុបចំណាយចរន្ត** | **140.132** | **142.173** | **150.405** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 67.558 | 67.558 | 72.287 |
| មិនមែនបន្ទុកបុគ្គលិក | 72.574 | 74.615 | 78.118 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 15.378 | 15.839 | 16.631 |
| **សរុបចំណាយមូលធន** | **16.000** | **16.000** | **16.000** |
| ជំពូក ២១: អចលកម្មរូបី | 16.000 | 16.000 | 16.000 |
| - គម្រោងវិនិយោគ | 16.000 | 16.000 | 16.000 |
| **៩.មន្ទីរជំនាញ** | **109.332** | **110.340** | **116.862** |
| **សរុបចំណាយចរន្ត** | **109.332** | **110.340** | **116.862** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 68.458 | 68.458 | 73.250 |
| មិនមែនបន្ទុកបុគ្គលិក | 40.874 | 41.882 | 43.612 |
| **១៨. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** | **167.258** | **170.209** | **179.626** |
| **សរុបចំណាយចរន្ត** | **167.258** | **170.209** | **179.626** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 62.165 | 62.165 | 66.517 |
| មិនមែនបន្ទុកបុគ្គលិក | 105.093 | 108.044 | 113.109 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 74.482 | 76.716 | 80.552 |
| **១.ក្រសួង** | **134.760** | **137.403** | **144.755** |
| **សរុបចំណាយចរន្ត** | **134.760** | **137.403** | **144.755** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 40.217 | 40.217 | 43.032 |
| មិនមែនបន្ទុកបុគ្គលិក | 94.543 | 97.186 | 101.723 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 74.482 | 76.716 | 80.552 |
| **៩.មន្ទីរជំនាញ** | **32.499** | **32.806** | **34.871** |
| **សរុបចំណាយចរន្ត** | **32.499** | **32.806** | **34.871** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 21.949 | 21.949 | 23.485 |
| មិនមែនបន្ទុកបុគ្គលិក | 10.550 | 10.858 | 11.386 |
| **១៩. ក្រសួងបរិស្ថាន** | **82.979** | **83.754** | **88.891** |
| **សរុបចំណាយចរន្ត** | **82.979** | **83.754** | **88.891** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 54.392 | 54.392 | 58.199 |
| មិនមែនបន្ទុកបុគ្គលិក | 28.587 | 29.362 | 30.692 |
| **១.ក្រសួង** | **37.503** | **37.954** | **40.111** |

# គម្រោងថវិកាឆ្នាំ ២០២១-២០២៣

## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២១ | គម្រោងថវិកាឆ្នាំ ២០២២ | គម្រោងថវិកាឆ្នាំ ២០២៣ |
|---|---|---|---|
| សរុបចំណាយចរន្ត | **37.503** | **37.954** | **40.111** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 19.736 | 19.736 | 21.117 |
| មិនមែនបន្ទុកបុគ្គលិក | 17.767 | 18.219 | 18.994 |
| ៩.មន្ទីរជំនាញ | **45.476** | **45.799** | **48.780** |
| សរុបចំណាយចរន្ត | **45.476** | **45.799** | **48.780** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 34.656 | 34.656 | 37.082 |
| មិនមែនបន្ទុកបុគ្គលិក | 10.820 | 11.143 | 11.699 |
| **២០. ក្រសួងអភិវឌ្ឍន៍ជនបទ** | **305.668** | **310.130** | **320.329** |
| សរុបចំណាយចរន្ត | **185.668** | **190.130** | **200.329** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 36.281 | 36.281 | 38.821 |
| មិនមែនបន្ទុកបុគ្គលិក | 149.387 | 153.849 | 161.508 |
| សរុបចំណាយមូលធន | **120.000** | **120.000** | **120.000** |
| ជំពូក ២១: អចលកម្មរូបី | 120.000 | 120.000 | 120.000 |
| - គម្រោងវិនិយោគ | 120.000 | 120.000 | 120.000 |
| ១.ក្រសួង | **253.974** | **257.548** | **264.679** |
| សរុបចំណាយចរន្ត | **133.974** | **137.548** | **144.679** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 14.217 | 14.217 | 15.212 |
| មិនមែនបន្ទុកបុគ្គលិក | 119.757 | 123.331 | 129.467 |
| សរុបចំណាយមូលធន | **120.000** | **120.000** | **120.000** |
| ជំពូក ២១: អចលកម្មរូបី | 120.000 | 120.000 | 120.000 |
| - គម្រោងវិនិយោគ | 120.000 | 120.000 | 120.000 |
| ៩.មន្ទីរជំនាញ | **51.694** | **52.582** | **55.650** |
| សរុបចំណាយចរន្ត | **51.694** | **52.582** | **55.650** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 22.064 | 22.064 | 23.609 |
| មិនមែនបន្ទុកបុគ្គលិក | 29.630 | 30.517 | 32.042 |
| **២១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | **1.161.674** | **1.162.996** | **1.168.465** |
| សរុបចំណាយចរន្ត | **1.161.674** | **1.162.996** | **1.168.465** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 45.681 | 45.681 | 48.878 |
| មិនមែនបន្ទុកបុគ្គលិក | 1.115.993 | 1.117.316 | 1.119.587 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 20.665 | 21.285 | 22.349 |

# គម្រោងថវិកាឆ្នាំ ២០២១-២០២៣

## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២១ | គម្រោងថវិកាឆ្នាំ ២០២២ | គម្រោងថវិកាឆ្នាំ ២០២៣ |
|---|---|---|---|
| ១.ក្រសួង | **1.103.989** | **1.104.877** | **1.107.829** |
| សរុបចំណាយចរន្ត | **1.103.989** | **1.104.877** | **1.107.829** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 20.381 | 20.381 | 21.807 |
| មិនមែនបន្ទុកបុគ្គលិក | 1.083.608 | 1.084.496 | 1.086.021 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 20.665 | 21.285 | 22.349 |
| ៩.មន្ទីរជំនាញ | **57.685** | **58.119** | **60.636** |
| សរុបចំណាយចរន្ត | **57.685** | **58.119** | **60.636** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 25.300 | 25.300 | 27.071 |
| មិនមែនបន្ទុកបុគ្គលិក | 32.385 | 32.819 | 33.565 |
| **២២. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** | **59.651** | **60.555** | **64.109** |
| សរុបចំណាយចរន្ត | **59.651** | **60.555** | **64.109** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 28.585 | 28.585 | 30.586 |
| មិនមែនបន្ទុកបុគ្គលិក | 31.066 | 31.970 | 33.523 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 3.773 | 3.886 | 4.081 |
| ១.ក្រសួង | **41.124** | **41.766** | **44.186** |
| សរុបចំណាយចរន្ត | **41.124** | **41.766** | **44.186** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 18.843 | 18.843 | 20.162 |
| មិនមែនបន្ទុកបុគ្គលិក | 22.281 | 22.923 | 24.024 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 3.773 | 3.886 | 4.081 |
| ៩.មន្ទីរជំនាញ | **18.526** | **18.789** | **19.923** |
| សរុបចំណាយចរន្ត | **18.526** | **18.789** | **19.923** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 9.742 | 9.742 | 10.423 |
| មិនមែនបន្ទុកបុគ្គលិក | 8.785 | 9.048 | 9.499 |
| **២៣. ក្រសួងធម្មការ និងសាសនា** | **69.737** | **70.155** | **74.652** |
| សរុបចំណាយចរន្ត | **69.737** | **70.155** | **74.652** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 54.011 | 54.011 | 57.792 |
| មិនមែនបន្ទុកបុគ្គលិក | 15.726 | 16.143 | 16.860 |
| ១.ក្រសួង | **24.629** | **24.836** | **26.331** |
| សរុបចំណាយចរន្ត | **24.629** | **24.836** | **26.331** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 16.254 | 16.254 | 17.392 |

# គម្រោងថវិកាឆ្នាំ ២០២១-២០២៣

## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២១ | គម្រោងថវិកាឆ្នាំ ២០២២ | គម្រោងថវិកាឆ្នាំ ២០២៣ |
|---|---|---|---|
| មិនមែនបន្ទុកបុគ្គលិក | 8.375 | 8.582 | 8.939 |
| **៩.មន្ទីរជំនាញ** | **45.108** | **45.318** | **48.321** |
| **សរុបចំណាយចរន្ត** | **45.108** | **45.318** | **48.321** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 37.757 | 37.757 | 40.400 |
| មិនមែនបន្ទុកបុគ្គលិក | 7.351 | 7.561 | 7.921 |
| **២៤. ក្រសួងកិច្ចការនារី** | **48.155** | **48.738** | **51.363** |
| **សរុបចំណាយចរន្ត** | **48.155** | **48.738** | **51.363** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 23.205 | 23.205 | 24.829 |
| មិនមែនបន្ទុកបុគ្គលិក | 24.950 | 25.533 | 26.534 |
| **១.ក្រសួង** | **19.936** | **20.205** | **21.187** |
| **សរុបចំណាយចរន្ត** | **19.936** | **20.205** | **21.187** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 7.406 | 7.406 | 7.924 |
| មិនមែនបន្ទុកបុគ្គលិក | 12.530 | 12.799 | 13.262 |
| **៩.មន្ទីរជំនាញ** | **28.219** | **28.533** | **30.177** |
| **សរុបចំណាយចរន្ត** | **28.219** | **28.533** | **30.177** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 15.799 | 15.799 | 16.905 |
| មិនមែនបន្ទុកបុគ្គលិក | 12.420 | 12.734 | 13.272 |
| **២៥. ក្រសួងសាធារណការ និងដឹកជញ្ជូន** | **691.451** | **700.818** | **722.405** |
| **សរុបចំណាយចរន្ត** | **391.451** | **400.818** | **422.405** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 78.654 | 78.654 | 84.160 |
| មិនមែនបន្ទុកបុគ្គលិក | 312.796 | 322.164 | 338.245 |
| **សរុបចំណាយមូលធន** | **300.000** | **300.000** | **300.000** |
| ជំពូក ២១: អចលកម្មរូបី | 300.000 | 300.000 | 300.000 |
| - គម្រោងវិនិយោគ | 300.000 | 300.000 | 300.000 |
| **១.ក្រសួង** | **630.704** | **639.585** | **657.236** |
| **សរុបចំណាយចរន្ត** | **330.704** | **339.585** | **357.236** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 34.381 | 34.381 | 36.788 |
| មិនមែនបន្ទុកបុគ្គលិក | 296.323 | 305.203 | 320.448 |
| **សរុបចំណាយមូលធន** | **300.000** | **300.000** | **300.000** |
| ជំពូក ២១: អចលកម្មរូបី | 300.000 | 300.000 | 300.000 |

# គម្រោងថវិកាឆ្នាំ ២០២១-២០២៣

## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២១ | គម្រោងថវិកាឆ្នាំ ២០២២ | គម្រោងថវិកាឆ្នាំ ២០២៣ |
|---|---|---|---|
| - គម្រោងវិនិយោគ | 300.000 | 300.000 | 300.000 |
| **៩.មន្ទីរជំនាញ** | **60.747** | **61.234** | **65.169** |
| **សរុបចំណាយចរន្ត** | **60.747** | **61.234** | **65.169** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 44.273 | 44.273 | 47.372 |
| មិនមែនបន្ទុកបុគ្គលិក | 16.474 | 16.961 | 17.797 |
| **២៦. ក្រសួងយុត្តិធម៌** | **142.136** | **143.742** | **152.393** |
| **សរុបចំណាយចរន្ត** | **142.136** | **143.742** | **152.393** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 84.218 | 84.218 | 90.113 |
| មិនមែនបន្ទុកបុគ្គលិក | 57.918 | 59.524 | 62.280 |
| **១.ក្រសួង** | **57.782** | **58.501** | **61.796** |
| **សរុបចំណាយចរន្ត** | **57.782** | **58.501** | **61.796** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 29.463 | 29.463 | 31.525 |
| មិនមែនបន្ទុកបុគ្គលិក | 28.319 | 29.038 | 30.271 |
| **១.១. យុត្តិធម៌** | **39.379** | **39.930** | **42.044** |
| **សរុបចំណាយចរន្ត** | **39.379** | **39.930** | **42.044** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 16.713 | 16.713 | 17.883 |
| មិនមែនបន្ទុកបុគ្គលិក | 22.666 | 23.217 | 24.161 |
| **១.២. តុលាកំពូល** | **6.955** | **7.023** | **7.466** |
| **សរុបចំណាយចរន្ត** | **6.955** | **7.023** | **7.466** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 4.674 | 4.674 | 5.001 |
| មិនមែនបន្ទុកបុគ្គលិក | 2.281 | 2.349 | 2.465 |
| **១.៣. សាលាឧទ្ធរណ៍** | **6.706** | **6.743** | **7.189** |
| **សរុបចំណាយចរន្ត** | **6.706** | **6.743** | **7.189** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 5.455 | 5.455 | 5.837 |
| មិនមែនបន្ទុកបុគ្គលិក | 1.251 | 1.288 | 1.352 |
| **១.៤. ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម** | **4.742** | **4.805** | **5.097** |
| **សរុបចំណាយចរន្ត** | **4.742** | **4.805** | **5.097** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 2.621 | 2.621 | 2.804 |
| មិនមែនបន្ទុកបុគ្គលិក | 2.121 | 2.184 | 2.293 |
| **៩.មន្ទីរជំនាញ** | **84.354** | **85.241** | **90.596** |

# គម្រោងថវិកាឆ្នាំ ២០២១-២០២៣

## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២១ | គម្រោងថវិកាឆ្នាំ ២០២២ | គម្រោងថវិកាឆ្នាំ ២០២៣ |
|---|---|---|---|
| **សរុបចំណាយចរន្ត** | **84.354** | **85.241** | **90.596** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 54.755 | 54.755 | 58.588 |
| មិនមែនបន្ទុកបុគ្គលិក | 29.599 | 30.486 | 32.009 |
| **២៧. ក្រសួងទេសចរណ៍** | **83.233** | **84.758** | **89.436** |
| **សរុបចំណាយចរន្ត** | **83.233** | **84.758** | **89.436** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 29.419 | 29.419 | 31.478 |
| មិនមែនបន្ទុកបុគ្គលិក | 53.814 | 55.339 | 57.957 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 20.859 | 21.485 | 22.559 |
| **១.ក្រសួង** | **60.874** | **62.110** | **65.402** |
| **សរុបចំណាយចរន្ត** | **60.874** | **62.110** | **65.402** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 16.720 | 16.720 | 17.890 |
| មិនមែនបន្ទុកបុគ្គលិក | 44.154 | 45.390 | 47.512 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 20.859 | 21.485 | 22.559 |
| **៩.មន្ទីរជំនាញ** | **22.359** | **22.648** | **24.034** |
| **សរុបចំណាយចរន្ត** | **22.359** | **22.648** | **24.034** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 12.699 | 12.699 | 13.588 |
| មិនមែនបន្ទុកបុគ្គលិក | 9.660 | 9.949 | 10.446 |
| **២៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | **132.996** | **133.784** | **139.564** |
| **សរុបចំណាយចរន្ត** | **116.496** | **117.284** | **123.064** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 63.263 | 63.263 | 67.691 |
| មិនមែនបន្ទុកបុគ្គលិក | 53.233 | 54.021 | 55.373 |
| **សរុបចំណាយមូលធន** | **16.500** | **16.500** | **16.500** |
| ជំពូក ២១: អចលកម្មរូបី | 16.500 | 16.500 | 16.500 |
| - គម្រោងវិនិយោគ | 16.500 | 16.500 | 16.500 |
| **១.ក្រសួង** | **78.273** | **78.763** | **80.897** |
| **សរុបចំណាយចរន្ត** | **61.773** | **62.263** | **64.397** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 18.474 | 18.474 | 19.767 |
| មិនមែនបន្ទុកបុគ្គលិក | 43.299 | 43.789 | 44.629 |
| **សរុបចំណាយមូលធន** | **16.500** | **16.500** | **16.500** |
| ជំពូក ២១: អចលកម្មរូបី | 16.500 | 16.500 | 16.500 |

# គម្រោងថវិកាឆ្នាំ ២០២១-២០២៣

# តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២១ | គម្រោងថវិកាឆ្នាំ ២០២២ | គម្រោងថវិកាឆ្នាំ ២០២៣ |
|---|---|---|---|
| - គម្រោងវិនិយោគ | 16.500 | 16.500 | 16.500 |
| **៩.មន្ទីរជំនាញ** | **54.723** | **55.021** | **58.668** |
| **សរុបចំណាយចរន្ត** | **54.723** | **55.021** | **58.668** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 44.789 | 44.789 | 47.924 |
| មិនមែនបន្ទុកបុគ្គលិក | 9.934 | 10.232 | 10.743 |
| **២៩. ក្រសួងធនធានទឹក និងឧតុនិយម** | **258.228** | **261.548** | **269.757** |
| **សរុបចំណាយចរន្ត** | **158.228** | **161.548** | **169.757** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 35.840 | 35.840 | 38.349 |
| មិនមែនបន្ទុកបុគ្គលិក | 122.388 | 125.708 | 131.408 |
| **សរុបចំណាយមូលធន** | **100.000** | **100.000** | **100.000** |
| ជំពូក ២១: អចលកម្មរូបី | 100.000 | 100.000 | 100.000 |
| - គម្រោងវិនិយោគ | 100.000 | 100.000 | 100.000 |
| **១.ក្រសួង** | **221.174** | **223.907** | **229.961** |
| **សរុបចំណាយចរន្ត** | **121.174** | **123.907** | **129.961** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 19.451 | 19.451 | 20.813 |
| មិនមែនបន្ទុកបុគ្គលិក | 101.723 | 104.456 | 109.149 |
| **សរុបចំណាយមូលធន** | **100.000** | **100.000** | **100.000** |
| ជំពូក ២១: អចលកម្មរូបី | 100.000 | 100.000 | 100.000 |
| - គម្រោងវិនិយោគ | 100.000 | 100.000 | 100.000 |
| **៩.មន្ទីរជំនាញ** | **37.054** | **37.641** | **39.796** |
| **សរុបចំណាយចរន្ត** | **37.054** | **37.641** | **39.796** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 16.389 | 16.389 | 17.536 |
| មិនមែនបន្ទុកបុគ្គលិក | 20.665 | 21.252 | 22.260 |
| **៣០. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** | **57.575** | **58.743** | **62.036** |
| **សរុបចំណាយចរន្ត** | **57.575** | **58.743** | **62.036** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 18.387 | 18.387 | 19.674 |
| មិនមែនបន្ទុកបុគ្គលិក | 39.188 | 40.356 | 42.362 |
| **៣១. អាជ្ញាធរសវនកម្មជាតិ** | **12.471** | **12.580** | **13.383** |
| **សរុបចំណាយចរន្ត** | **12.471** | **12.580** | **13.383** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 8.796 | 8.796 | 9.412 |
| មិនមែនបន្ទុកបុគ្គលិក | 3.675 | 3.784 | 3.971 |

# គម្រោងថវិកាឆ្នាំ ២០២១-២០២៣

## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២១ | គម្រោងថវិកាឆ្នាំ ២០២២ | គម្រោងថវិកាឆ្នាំ ២០២៣ |
|---|---|---|---|
| **៣២. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | **213.789** | **215.768** | **226.068** |
| **សរុបចំណាយចរន្ត** | **213.789** | **215.768** | **226.068** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 98.605 | 98.605 | 105.508 |
| មិនមែនបន្ទុកបុគ្គលិក | 115.184 | 117.163 | 120.560 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 47.125 | 47.339 | 47.705 |
| **១.ក្រសួង** | **156.175** | **157.733** | **164.260** |
| **សរុបចំណាយចរន្ត** | **156.175** | **157.733** | **164.260** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 55.050 | 55.050 | 58.904 |
| មិនមែនបន្ទុកបុគ្គលិក | 101.125 | 102.682 | 105.356 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 47.125 | 47.339 | 47.705 |
| **៩.មន្ទីរជំនាញ** | **57.614** | **58.036** | **61.808** |
| **សរុបចំណាយចរន្ត** | **57.614** | **58.036** | **61.808** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 43.555 | 43.555 | 46.604 |
| មិនមែនបន្ទុកបុគ្គលិក | 14.059 | 14.481 | 15.204 |
| **៣៣. ស្ថាប័នប្រឆាំងអំពើពុករលួយ** | **38.206** | **38.610** | **41.019** |
| **សរុបចំណាយចរន្ត** | **38.206** | **38.610** | **41.019** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 24.493 | 24.493 | 26.208 |
| មិនមែនបន្ទុកបុគ្គលិក | 13.713 | 14.117 | 14.811 |
| **៣៤. ក្រសួងមុខងារសាធារណៈ** | **55.882** | **56.424** | **59.135** |
| **សរុបចំណាយចរន្ត** | **55.882** | **56.424** | **59.135** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 25.432 | 25.432 | 27.212 |
| មិនមែនបន្ទុកបុគ្គលិក | 30.450 | 30.992 | 31.922 |
| **១.ក្រសួង** | **35.643** | **35.882** | **37.363** |
| **សរុបចំណាយចរន្ត** | **35.643** | **35.882** | **37.363** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 15.311 | 15.311 | 16.383 |
| មិនមែនបន្ទុកបុគ្គលិក | 20.332 | 20.571 | 20.980 |
| **៩.មន្ទីរជំនាញ** | **20.239** | **20.542** | **21.771** |
| **សរុបចំណាយចរន្ត** | **20.239** | **20.542** | **21.771** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 10.121 | 10.121 | 10.829 |
| មិនមែនបន្ទុកបុគ្គលិក | 10.118 | 10.421 | 10.942 |

# គម្រោងថវិកាឆ្នាំ ២០២១-២០២៣

# តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២១ | គម្រោងថវិកាឆ្នាំ ២០២២ | គម្រោងថវិកាឆ្នាំ ២០២៣ |
|---|---|---|---|
| **៣៥. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** | **48.017** | **48.686** | **51.567** |
| **សរុបចំណាយចរន្ត** | **48.017** | **48.686** | **51.567** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 24.764 | 24.764 | 26.498 |
| មិនមែនបន្ទុកបុគ្គលិក | 23.253 | 23.922 | 25.070 |
| **១.ក្រសួង** | **28.204** | **28.597** | **30.262** |
| **សរុបចំណាយចរន្ត** | **28.204** | **28.597** | **30.262** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 14.159 | 14.159 | 15.150 |
| មិនមែនបន្ទុកបុគ្គលិក | 14.045 | 14.438 | 15.112 |
| **៩.មន្ទីរជំនាញ** | **19.813** | **20.089** | **21.305** |
| **សរុបចំណាយចរន្ត** | **19.813** | **20.089** | **21.305** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់រង្វាន់) | 10.606 | 10.606 | 11.348 |
| មិនមែនបន្ទុកបុគ្គលិក | 9.208 | 9.484 | 9.957 |
| **ចំណាយផ្សេងៗ** | **787.732** | **790.901** | **827.794** |
| - ឧបត្ថម្ភធនដល់រដ្ឋបាលរាជធានី ខេត្ត (ការប្រគល់មុខងារ-មន្ទីរសុខាភិបាល) | 657.031 | 660.200 | 697.093 |
| - ឧបត្ថម្ភធនដល់រដ្ឋបាលក្រុង ស្រុក (ការប្រគល់មុខងារ-ការអប់រំកុមារតូច បឋមសិក្សា និងក្រៅប្រព័ន្ធ) | 130.702 | 130.702 | 130.702 |